ព្រះរាជបណ្ណាល័យកម្ពុជា

KAMBUJASURIYÂ

កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែម៉ាត់ក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ២

គណៈរដ្ឋមន្ត្រីនឹងសម្តេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

BIBLIOTHEQUE ROYALE DU CAMBODGE

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨៤

ឆ. ស. ១៩៤២

បញ្ជីរឿង

ទំព័រ

១ — ព្រះរាជពិធីរាជាភិសេក នៃព្រះបាទសម្តេចព្រះនរោត្តម-សីហនុ ឬ៉ែន ព្រះចៅក្រុងកម្ពុជាធិបតី (តមកនឹងចប់) ៣

២ — ប្រវត្តិទង់ប្រចាំជាតិខ្មែរ ២៩

៣ — ប្រវត្តិអក្សរសាស្ត្រខ្មែរ (សង្ខេប) លោកសីវិសថាងហ្វាងសាលាបារាំងសែសបុងបូពាំប្រទេសរៀបរៀង (តមក) ៣៧

៤ — ជ្ឈាប់រឹទ្ធរបណ្តិត (៣ក្យកាព្យ) ៤២

៥ — ប្រវត្តិពួកឧបាសក-ឧបាសិកា ជាសាវកសាវិការបស់ព្រះពុទ្ធជាម្ចាស់ (តមក) : ទី ២ ប្រវត្តិសុទត្តគហបតី ៤៥

៦ — ពង្សាវតារភោម ស្រែង់យកអំពីពោលចារឹកផ្សេងៗក្នុងពង្សាវតារលោក (តមក) . ៤៧

៧ — រឿងព្រៃនខ្មែរ «រឿងដឹងសង្ងដឹង អំបែងសង្ងអំបែង» ៥១

រូបគ្រឿងរឿង

រូបប្រាសាទបន្ទាយស្រី - ពាសាងក្នុងសម័យនៃការបង្កាក់ពុងចំរើនបរិបូណ៌ កាលពីសតវត្សរ៍ទី ១៦ នៃពុទ្ធសករាជ ១

TABLE DES MATIÈRES

Pagese

1. Cérémonies du Couronnement de S. M. Préas Bat Samdach Préas Norodom-Sihanouk Varman, Roi du Cambodge (suite et fin)..... 3

2. Histoire du drapeau Khmèr..... 29

3. Littérature cambodgienne, par Monsieur G. Cœdès, Directeur de l'École française d'Extrême-Orient (suite)..... 37

4. Chbab-Vidhurapandit (poème)..... 42

5. Vies des disciples laïcs du Buddha. La vie de Sudatta-Gahapiti..... 45

6. Histoire de Rome. Extrait de divers documents de l'histoire universelle (suite)..... 47

7. Conte populaire cambodgien inédit :

"Tesson pour tesson, herminette pour herminette"..... 51

HORS TEXTE.

Banteai Srei—Exemple caractéristique de l'art Khmèr à son apogée (X^e siècle)..... 1

រូបប្រាសាទបន្ទាយស្រី ក្នុងសម័យនៃការរចនាកំពុងចំរើនបរិបូណ៌
ក្នុងសតវត្សរ៍ទី ១៦ នៃពុទ្ធសករាជ

ព្រះរាជពិធីរាជាភិសេក

ព្រះបាទសម្តេចព្រះនរោត្តម-សីហនុ វ្រ៉ែន ព្រះបរមរតនកម្ពុជាធិបតី

(តទៅ ទំព័រ ២)

តែសេចក្តីទុក្ខលំបាកនេះ មិនអាចរម្ងាប់ទ្បូវសេចក្តីយកចិត្តទុកដាក់ខ្នះខ្នែងរបស់យើងបាន ទីឯបណ្តាលឲ្យយើងក្លេចអំពីកិច្ចធ្ងន់របស់យើង ដែលត្រូវតែលាងរុំរបួសដំបៅរបស់ស្រុកឲ្យបានសះជាឆាប់ កុំបីបណ្តែតបណ្តោយធ្វេសទុកឲ្យយូរតទៅឥតអង្គឹមាន ត្រូវតែប្រដូងប្រជានគន្លឹះឲ្យបានចំរើនទៅខាងអនាគត ដើម្បីជាទីអាចឲ្យយើងមានសេចក្តីកក់ក្តៅសង្ឃឹមទុកចិត្តបានកាល់ប្រៀប ។

ខ្ញុំមានព្រះតំរិះយល់ថា នឹងយកព្រះពរជ័យទុកជាក់ក្នុងការនេះឲ្យអស់ពីព្រះពរជ័យ ហើយខ្ញុំប្រកាសពេញឥន្ទ្រិយ៍ដល់អាណាប្រជាពលរដ្ឋរបស់ខ្ញុំក្នុងវេលាថ្ងៃនេះ ដើម្បីឲ្យសម្រេចតាមការដ៏ប្រពៃនេះ អំពីដែលខ្ញុំមានព្រះពរជ័យតែម្តងឲ្យធ្លើជូរច្រះ គឺខ្ញុំសំរេចតាមព្រះពរជ័យដ៏ខ្លាំងរបស់ព្រះករុណា ព្រះបរមរតនកោដ្ឋ ។

អំពីប្រទេសនានា ដែលភ្ជាប់ចុះអន្តរកាយទៅយ៉ាងណាដោយច្រើនអាស្រ័យហេតុមកអំពីគំនិតគិតចំពោះតែការផ្តល់ប្រយោជន៍មួយៗ ខ្លាំងពេកមកអំពីគ្មានសេចក្តីស្មោះត្រង់ចំពោះដល់ការដែលប្រយោជន៍ទ្បូវទៅខាងអស់

ត្រូវបូមកអំពីច្បាប់ការពារតែប្រយោជន៍ផ្ទាល់ខ្លួនលើសលុបពេកនោះ ប្រទេសជាតិនោះដែលនឹងរើចូលទៅកាន់សេចក្តីចំរើនថ្កុំថ្កើងឡើងវិញដោយរហ័សឆាប់បាន ចួនណាក៏អាស្រ័យហេតុទៅតាមតែរបៀបដែលរៀបចំការប្រព្រឹត្តិសាសនានឹងការប្រព្រឹត្តិកាន់ចិត្តគំនិតឲ្យបានមានជម្លៀសបួលដូចដើមឡើងវិញដូច្នោះតែប៉ុណ្ណោះដែរ ។

តាមពង្សាវតាររៀងមក ត្រូវបានឃើញបណ្តាលឲ្យរើខ្លួនរួចទៅកាន់សេចក្តីថ្កុំថ្កើងឡើងវិញតាមន័យដូច្នោះក៏ច្រើន ហើយកាលវេលាប៉ុន្មានឆ្នាំតមកអំពីជ័យជំនះកង្គឆ្នាំ ១៨១៨ ក៏មានបណ្តាលហេតុកើតឡើងជាគួរយ៉ាងដ៏វែងនាដូច្នោះនៅប្រទេសនុរុបស្រាប់ហើយ ។ តែការរើខ្លួនរួចយ៉ាងប្រពៃ ដែលទ្រង់ព្រះពើនឹកឃើញក្នុងព្រះរាជតំរិះសព្វថ្ងៃគួរយ៉ាងមហាវិសេសនោះ គឺការតុបតែងរៀបចំឲ្យបានចំរើនឡើងវិញរបស់លោកសេនាប្រមុខ ប៉ែតាំង នៅនគរចុកាំងសែស ដែលបានខូចរងអស់ពីយ៉ាងខ្មង់រៀង ឆ្នាំមកហើយ ។ ចេះតែរៀបរៀបកិច្ចការនានា ជាកំពូលសម្រាប់ស្រុកឲ្យបានស្រួលឡើងវិញ ហើយសព្វថ្ងៃនេះកំពុងសើរើបន្តិចម្តងៗ ទៅកាន់ខ្ពស់ថ្កុំថ្កើងលោកដូចកាលអំពីដើមឡើងវិញហើយ ។

ទ្រង់មិនគាចនឹងជ្រើសរើសគំរូឯណាឲ្យប្រពៃលើសជាងពីគំរូរបស់លោកសេនាប្រមុខ ប៉ែតាំង ដែលលោកធ្វើឲ្យបានកើតការស្រួលឡើង

វិញដោយអស្ចារ្យដូច្នេះឡើយ ។ សេចក្តីនេះ សូមលោកអាម៉ាល់ផ្ទាប
តែខ្ញុំមានសេចក្តីគោរពចំពោះដល់ប្រាជ្ញាគំនិតរបស់លោកព្រឹទ្ធាចារ្យ
ដែលជាអ្នកកាន់តាប់ភ័ព្វសំណាងនៃនគររបស់លោក ហើយខ្ញុំនឹង
អធិប្បាយឲ្យអាណាប្រជាកស្តេរបស់ខ្ញុំ នឹងរៀបតិច្ចការដែលអាច
ទាំងឲ្យបានសេចក្តីខុដ្ឋុខុត្តមដល់ព្រះនគរតែម្តង ។

ឯតិច្ចធំក្នុងរៀបដូច្នោះ គោងចាត់ការឲ្យមានអំណាច លុះមាន
អំណាចដូច្នោះហើយគោងតម្រូវឲ្យខ្លួលការខុសត្រូវដូច្នោះផង ។

លោកមេទ័ពជើងទឹកជឹគូក្ស្រាយកសហរដ្ឋឥណ្ឌូស៊ីន

ចំពាក់មកពីដីថ្វាយព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម-សីហនុ ប្រ៊ុយ

លុះបានចំពេញព្រះពរជតិជ័តាមទំនៀម ក្នុងព្រះទីន័ងទេវាវិនិច្ឆ័យ
តំរង់ ៣ ថ្ងៃហើយ ដល់ថ្ងៃអង្គារ ៤ កើតខែកត្តិក (២៨ តុលា ១៩៦១)
ជាថ្ងៃចំរើនព្រះជន្មវស្សា គឺថ្ងៃដែលព្រះករុណាខ្ញុំបែរសូត្រ នោះតាំង
ពីព្រលឹម ព្រះករុណាខ្ញុំស សេ្តចចេញមកកាន់ព្រះទីន័ងទេវាវិនិច្ឆ័យ
ថ្វាយបង្គំព្រះពុទ្ធរូប ហើយព្រះសង្ឃសូត្រជយន្តោថ្វាយជ័យមង្គលរួច
ព្រះករុណាខ្ញុំខ្លួលលោកអធិបតីនៃពលការអាណាព្យាបាលក្រុងកម្ពុជា
ព្រះសង្ឃនាយកទាំង ២ គណៈ រដ្ឋមន្ត្រីទាំង ៩ នឹងសម្តេចឥស្សរកិច្ចធិបតី
ចាងហ្វាងជាគ្នា រួចព្រះករុណាទៅយាងឡើងលើព្រះបល្ល័ង្កត្រែមព្រះ

មហាបុស្សបុកតាំងនៅមុខព្រះទីន័ងទេវ ។ ព្រះកុណ្ឌាទ្រង់ប្រតិស្ឋាន
លើផែនមាស ក្រាលលើស្នឹកឧត្តរព្រឹក្ស សម្តេចឥសីកញ្ចាធិបតីថ្វាយ
សង្ឃជយព្រឹក្ស ព្រះកុណ្ឌាទ្រង់ទទួលភាន់ដោយព្រះហស្តស្តាំជាព្រះ
តេជះខេស្តា ហើយទ្រង់ឈមព្រះភក្ត្រទៅទិសបូព៌ា ទកញ្ជាហោពធិបតី
ចាប់ហ្វាងក្រមហោពសូត្រប្រកាសអញ្ជើញទៅគា សូមចំរើនសិរីសួស្តី
ជ័យមង្គលថ្វាយព្រះកុណ្ឌាទៅទីពានទេព្តា ហើយថ្វាយកាំភ្លើង ២១
ណាត់ថ្វាយជាព្រះកិត្តិយស ទៅវេលាដែលលោកឡឺវេស៊ីដង់ត៍សុប៉ែរយើរ
ព្រះចៅហ្លួងព្រះបាង សម្តេចព្រះបរមកជបិតាសុពម្ចិត សម្តេចព្រះ
ហគុណាមុនីរេត ព្រះសង្ឃនាយកទាំងពីរគណៈ សម្តេចព្រះឥសីកញ្ចាថ្វាយ
ព្រះសិទ្ធិសេ ទ្រង់ស្រង់រួចហែស្តេចចុះមកលាងព្រះបាទាដោយទឹកដូង
ទឹកអប់កង់ថាសមាស ។

ព្រះកុណ្ឌាទ្រង់គ្រឿងព្រះពស្ត្រព្រះកូសាផាយរត្តកម្ពលពេញព្រះ
កាយ តាមលំអានព្រះមហាក្សត្រពីបុរាណ សម្តេចឥសីកញ្ចាធិបតី
ហែមុខ ទ្រង់យាងចេញមកកន្លែងព្រះទីន័ងទៅវិនិច្ឆ័យទទួលលោកឡឺវេ-
ស៊ីដង់ត៍សុប៉ែរយើរនៃប្រទេសកម្ពុជា ព្រះសង្ឃនាយកទាំង ២ គណៈ
ព្រះពជវង្សានុវង្ស សេនាបតី អាហ្មាត្យមន្ត្រីមុខមន្ត្រីក្នុងព្រះពជាណាចក្ត
ម៉ឺនមន្ត្រីពជការប្រតិតគូព៌ាត់ ហើយទ្រង់ទទួលព្រះបាទសម្តេចព្រះស៊ីស-
វ៉ត្ថាវង្ស ព្រះចៅហ្លួងព្រះបាង លោកកុន្ស៊ូ វេស៊ីដង់ត៍សុប៉ែរយើរនៅ

រៀងចន្លុះនឹងព្រះពាជវង្សានុវង្សដែលតាមហែមក លោកហ្សាក់ងាយ
សេនាបតីក្រសួងព្រះឃ្លាំងនៃក្រុងហ្សូនឹងតុនកំងជាព្រះពាជទំរើនៃព្រះចៅ
ចាវជាយប្រទេសអណ្ណាម លោកវ៉ាល់តូវ៉ែរណើរនៃប្រទេសកូសាំងស៊ីន ។

លោកឡឺតូវ៉ែរណើរហ្សែណាល់ដែលទំស្រុតដំណើរតាមផ្លូវរោ-
កាសពីហាណូយតាំងពីពេលព្រឹកមក ទើបបានមកដល់ក្រុងក្នុងពេញ
នៅវេលាម៉ោង ១០ ព្រឹកមិនខាន់ព្រះពាជពិធីស្រង់ព្រះសិទ្ធរសឡើយ ។

លុះចៅក្នាក់ងារសម្រេចកិច្ចតាមទំនៀមថ្វាយ ព្រះករុណាសព្វគ្រប់
ហើយ ទើបលោកអធិបតីនៃប្រទេសឥណ្ឌូស៊ីន លោកឡឺវេស៊ីដង់ស៊ុ-
ប៉ែរយើរក្រុងកម្ពុជា ចូលថ្វាយបង្គំព្រះករុណាជួបជុំប្រជុំធំ នាំពណិដ៏មាន
ថ្វាយសព្វសាធុការពរពីរដ្ឋបាលបារាំងវិសេស ដែលទំនុកបំរុងក្រុងបារាំង-
វិសេស ហើយអញ្ជើញនឹងហែស្តេចឡើងប្រថាប់លើព្រះបល្ល័ង្កវ៉ែន
គ្រោមព្រះមហាសេតច្ឆត្រ ៩ ជាន់ មានចុងកាំក្រើង ២១ ណាត់ថ្វាយជា
ព្រះកិត្តិយស ជាទីសំគាល់ថាព្រះករុណាថ្មីទ្រង់សោយរាជសម្បត្តិគ្រោម
ព្រះមហាសេតច្ឆត្រហើយ ។ គ្រានោះ សម្តេចព្រះឥសីកត្តាធិបតីអញ្ជើញ
ព្រះមកុដរាជ្យជូនទៅលោកឡឺតូវ៉ែរណើរហ្សែណាល់ ។ បំពាក់ថ្វាយព្រះ
ករុណាតាងនាមរដ្ឋបាលបារាំងវិសេស ។ លោកឡឺវេស៊ីដង់ស៊ុប៉ែរយើរ
អញ្ជើញព្រះខាន់ពាជ្យថ្វាយព្រះករុណា ។ ទ្រង់ទទួលដោយព្រះហស្តស្តាំ

ហើយសេនាបតីនឹងចៅក្រសួង ថ្វាយគ្រឿងសម្រាប់ពាជ្យតាមទំនៀម ។
ខ្ញុំពុជការគ្រាបថ្វាយបង្គំព្រះករុណា ។

លោកអធិបតីសម្រាប់ផ្នែកសាសនាថ្លែងសុន្ទរកថាថ្វាយសតុសាធុការ
ពរ ។

ព្រះពជគ្រូហែស្តេចចុះមកគង់នាប់លោកឡឺតូវរណើរហ្វិណាល់
នឹងលោកឡឺវេស៊ីជង់ស៊ុបែរាយើរ រំលងនោះមានពិធីបង្ហិលពពិលថ្វាយ ។

ដល់ថ្ងៃពុធ ១០ កើតខែកត្តិក (២៩ខែតុលា ១៩៦១) មានពិធីហែ
ប្រទក្សិណព្រះគ្រងគ្នំពេញ ព្រះករុណាព្រះមហាក្សត្រថាប់លើព្រះ
ពជយានមាស ហែបេញព្រះគ្រងព្រះបរមពជាំងតាមទ្វារធំខាងមុខ ដល់មាត់
ទ្វារ ព្រះករុណាព្រះបរមនាថសីហនុ ព្រះពរជ័យអំពីតុមាកកុមារីកូនសិស្សនៅ
ក្រុងភ្នំពេញ ដែលកាន់ទង់ជាតិខ្មែរ-ចាក់ពីនឹងកាន់ផ្កាចាំថ្វាយព្រះពរជ័យ-
មង្គល រួចទើបចូលក្នុងក្បួនធំដែលរៀបត្រៀមចាំស្រាប់ ។ លុះក្បួនព័ទ្ធ
ដល់ទៅវត្តភ្នំព្រះករុណាព្រះបរមនាថសីហនុឡើងទៅលើព្រះពន្លាក័កហើយឡើងគង់លើ
ព្រះពជរថមាសតព្រះពជដំណើរទៅទៀត ដល់មុខអនុស្សាវរីយ៍មហា-
សង្គ្រាម ទើបចូលឈប់លើព្រះពន្លាក័កផ្ទាស់ព្រះមកុដបេញ ព្រះ
មហាវិញ ហើយឡើងគង់លើព្រះទីនឹងអស្សតរ តព្រះពជដំណើរទៅ
ដល់មុខមន្ទីរពជការអាណាព្យាបាលទើបព្រះបរមនាថចូលឈប់នៅទីនោះ ដែល

លោកឡឺតូវែរណើរហ្សូណាល់ លោកឡឺវេស៊ូជនត៍សុប៉ែរយើរចាំទទួល ហើយទ្រង់ផ្ញាស់ព្រះមាលាចេញ ទ្រង់ព្រះមាលាប្រពាតហើយទើបឡើងគង់លើព្រះទីន័ងតដន្លួបន្តព្រះពជដំណើរប្រទក្សិណព្រះនគរមកដល់ព្រះបរមពជវាំង ដែលមានចាញ់កាំភ្លើង ២១ ណាត់ហ្វាយជាព្រះកិត្តិយស ហើយទ្រង់យាងឡើងទៅលើព្រះពន្ធាគ័កសម្រាន្តកំមៃ ដែលលោកអធិបតីនៃប្រទេសឥណ្ឌូស៊ីនទីន លោកឡឺវេស៊ូជនត៍សុប៉ែរយើរសម្តេចព្រះបរមពជបិតាហៅចុះមកកាន់ទៅវិនិច្ឆ័យវិញ ។

សុន្ទរកថាបន្ទូលក្នុងឱកាសរាជាភិសេក

ឯដោយពិតនោះ ដែលនទីនសន្ទតជាមនុស្សត្រូវសំគាល់តាមត្រូល តាមក្រមសន្ទាសនទីនតាមប្រទេសដែលខ្លួនកើតនទីនរស់នៅ គឺតាមសេចក្តីសាមគ្គីជាតិដូច្នេះហើយ ដែលទ្រង់ប្រាថ្នាសុំពរកនៅវេលាថ្ងៃនេះជាប្រយោជន៍ដើម្បីនទីនរើរៀបនគរកម្ពុជាជាថ្មីឲ្យបានស្រួលឡើង ។

ឯការពរកនេះ គឺបំណងឲ្យបណ្តាជនក្នុងព្រះនគរមានគំនិតត្រិតដល់អាណាប្រយោជន៍សាធារណៈ បើពោលឲ្យចំទៅទៀតគឺថាត្រូវឲ្យមានសេចក្តីស្មោះត្រង់ចំពោះដល់ប្រយោជន៍សាធារណៈ ត្រូវឲ្យយកចិត្តទុកដាក់ធ្វើការពាំងពួន ឲ្យស្រឡាញ់នូវសេចក្តីសុចរិត ។ ឯកិច្ចធ្វើការ

នេះជាមត៌កសំពាប់ជនកូនលោក ហើយជនកូនលោកត្រូវតែធ្វើនឹងចៀសវាងពុំបាន តែមានទម្រាំជាតិជាច្រើនដែលមានចេតនាចង់ចៀសវាងពីកិច្ចធុរៈធ្វើការនេះឯង ហើយផ្អែកលើអ្នកដទៃឲ្យធ្វើការជាដំនួសខ្លួន ត្រូវកំចាត់បង់កុំឲ្យមានគំនិតខុសដូច្នោះទៀតឡើយ ត្រូវខិតខំតាំងខ្លួនឲ្យមានកើតខ្លឹងជាអ្នកមានប្រយោជន៍ដល់ស្រុកឲ្យមានចំនួនច្រើនឡើងក្នុងព្រះនគរដូចកាលកូនានាពាក្យក្រែកូនតាបាំងសេស ដែលមានពួកជនដូច្នោះជាច្រើនខិតខំយកចិត្តទុកជាក់រឿងពលរដ្ឋ ធ្វើឲ្យបានសិរីជយមង្គលដល់មហាក្សត្រៃបស់គេ ដូច្នេះអំណើះតទៅត្រូវតែខ្ញុំពជការគ្រប់ដំណែងដែលទទួលអំណាចអំពីទ្រង់ព្រះសព្រះពជមានទៅឲ្យសព្វរឿងខ្លួននោះ ខំខ្នះខ្នែងធ្វើការឲ្យហ្មត់ចត់ដោយសុចរិតនឹងក្រឹត្យាហើយខិតខំខ្ជិលច្រអូសឲ្យអស់ពីកំឡាំងកាយនឹងចិត្តរបស់ខ្លួន កុំឲ្យច្បាច្បាយកតែសុខហើយនឹងធ្វើការមុខជារគេចវេះមិនឲ្យមានការៈទទួលខុសត្រូវលើខ្លួនហើយឥតមានប្រយោជន៍អ្វីដូចកាលមុនទៀត តែត្រូវឲ្យមានដើមគំនិតរបស់ខ្លួនជាមេនាយក ត្រូវសង្វាតធ្វើការឲ្យបានសំរេចហើយឲ្យបានល្អផង ។

សុំឲ្យពួកយុវជនដែលមានចំណេះវិជ្ជាកូនព្រះនគរទាំងប៉ុន្មានយល់តាមព្រះពជតម្រិះនេះ ហើយលុះបានប្រកបកិច្ចការងារឯណា ត្រូវឲ្យទទួលប្រតិបត្តិតាមរបៀបដែលទ្រង់បានរំលេចមកលើខ្លួន គឺ "ធ្វើការជាប្រយោជន៍ស្រុក" ។

សេចក្តីស្រឡាញ់ជាតិរបស់ខ្លួន ដែលទ្រង់តែងតែប្រយោជន៍ដើម្បីឲ្យបានមាំមួនខ្ជាប់ឆ្ងើងនេះ មិនគួរបណ្តាលឲ្យអស់អាណាប្រជាពលរដ្ឋភ្លេចឡើយ ថានៅត្រកាត់ដែនស្រុកយើងតទៅ មានទាំងប្រទេសឯទៀតដែលព្រះនគរបានរួបរួមចងមិត្តភាពគ្នា ជាប្រយោជន៍ធំផ្សាល់ជីវិតលើសលុបអំពីកិច្ចការលក្ខណៈដែលបុះខសញ្ញាជាតិមិត្តរួមាំមួនទំនាក់ទាក់តាមរបៀបច្បាប់នោះទៅទៀត ។

រឿងនេះ ប្រការ ១ គឺទ្រង់អធិប្បាយអំពីប្រទេសឥណ្ឌូស៊ុនដែលដើមឡើយគ្រាន់តែជាទីរួមដែនតវាមួយគ្នាជានាមប៉ុណ្ណោះទេ តែដល់មកកន្លងប៉ុន្មានឆ្នាំមុននេះ បានរួបរួមគំនិតគ្នាចំរើនឡើងរឿងៗមកលុះត្រាតែកើតឡើងជាក្រុមសហរដ្ឋ ១ យ៉ាងមាំមួន កាលដើមគិតស្មានថាជាការរួបរួមគ្នាតែដោយគំនិតបន្តិចបន្តួចប៉ុណ្ណោះទេ តែដោយបានប្រែស្រ័យគ្នាទៅវិញទៅមកជាបិតថែរមាំមួនឡើង មានមេត្រីភាពគ្នាដោយដឹងស្គាល់ជម្លៃគ្នាទៅវិញទៅមកកាន់តែជ្រួតជ្រាបខ្លាំងឡើងហើយបានស្រុះចិត្តទទួលបង់ភាគជាមួយគ្នាកងការពារប្រទេសឥណ្ឌូស៊ុនកាលលើកមុនមិញនេះទៀតនោះ ទើបបណ្តាលរួបរួមជាសហរដ្ឋនេះឡើង ។

តំនិតដែលរួបរួមបង្កើតឡើងនៅសហរដ្ឋនេះ ទើបបានបញ្ជាក្រសួងជួបជុំជំនុំការរួបរួមគ្នាក្នុងក្រុមមហាសន្និបាតដែលទើបបង្កើតថ្មី ។

គួរតែកម្មវិធីជួយឧបត្ថម្ភដល់ក្រុមសហរដ្ឋថ្មីនេះហើយ ដោយក្រុមនេះអាចនឹងបណ្តាលឲ្យមានច្របោលជនចំពោះខ្លួន នោះកម្មវិធីដែលនឹងមានមេត្រីជួយឈ្មីធ្លាលឬជួយឧបត្ថម្ភអ៊ីជល់ក្រុមនោះ កុំបីមើលចំណាំកង្វល់កិច្ចការឯណាដែលមិនគួរមើលចំណាំនោះឡើយ ។

ឯប្រទេសឥណ្ឌូស៊ុននេះគ្រាន់តែជាភាគ១នៃប្រទេសកាជរបស់នគរបាល់ធំសែសប៉ុណ្ណោះទេ ហើយកម្មវិធីដែលទៅកង្វល់ដែនប្រទេសឥណ្ឌូស៊ុន ក៏ពាក់ព័ន្ធលក្ខណ៍ទៅប្រទេសកាជរបស់បាល់ធំសែសដែលជាតំរួមប្រទេសច្រើននោះដែរ ក្នុងប្រទេសកាជរបស់បាល់ធំសែសតាំងអស់មានមនុស្សចំនួន ១០០ លាននាក់ មានទំហំដីធំជាងកម្មវិធីចំនួន ៥០ ដង ។

គួរតែពិចារណាឲ្យឃើញឡើងថា ដោយសារមកអំពីមានប្រទេសកាជយ៉ាងធំណាស់លៀបដូច្នេះ បានជានគរយើងមិនអាចរលាយទៅបាន ហើយមួយវិញទៀត ដោយមានចាត់ចែងធ្វើការក្នុងប្រទេសកាជនោះបានចំរើនឡើងរឿងរាបជាបមកនោះ គង់មានថ្ងៃណាយើងនឹងមានសិរីជយមង្គលដូចកាលបុព្វណាដើមឡើងវិញជាមិនខាន ។

ដូច្នេះ ក្រែអំពីសេចក្តីសាមគ្គីដែលត្រូវជួយឈ្មីធ្លាលដល់ក្រុមសហរដ្ឋដែលទ្រង់ទើបអធិប្បាយឲ្យដឹងហេតុមកខាងលើនេះ ទ្រង់សុំឲ្យ

អាណាប្រជាពលរដ្ឋមានគំនិតដឹងយល់តាមរបៀបដែលអធិប្បាយអំពីប្រទេសកាជនោះផង ។

កម្ពុជវដ្ត សព្វថ្ងៃនេះគេមិនមែនបដិសេធឲ្យនៅតែឯកឯងដដែលនោះទេ ដែលមានកំឡាំងអន់ថយបន្តិចនេះគឺដោយមានគ្រោះកាលគ្រោះនគរអាណាព្យាបាលមានទុក្ខលំបាកនៅប្រទេសនរុប លុះកាលណាសម័យហេតុត្រឡប់មកជាស្រួលដូចធម្មតាឡើងវិញ ទ្រង់មានព្រះរាជតម្រិះយល់ដាក់ច្បាស់ណាស់ថា ទឹងបានរុងរឿងឡើងវិញជាប្រាកដតែត្រូវឲ្យទន្ទេរមួយៗក្នុងប្រទេសកាជមានសេចក្តីបារម្ភខំយកចិត្តទុកដាក់សំរេចតាមការដែលខ្លួនត្រូវធ្វើចំពោះដល់ប្រទេសកាជផងទើបបាន ត្រូវឲ្យដឿតុកចិត្តយ៉ាងខ្ពស់ប្រពៃដូចទ្រង់ធ្វើចំពោះដល់ទន្ទេរជាក់ផងសែសនឹងកិច្ចការដែលលោកសេនាប្រមុខសើរើធ្វើឲ្យបានចំរើនឡើងវិញ ។

ទ្រង់មិនមែនមានបំណងអធិប្បាយចំពោះតែអំពីរបៀបគំនិតធំៗដែលមានប្រយោជន៍ក្នុងការធ្វើឲ្យបានចំរើនឡើងវិញដល់ទន្ទេរប៉ុណ្ណោះហើយឥតអធិប្បាយអំពីរបៀបទំនៀមទម្លាប់ថ្មស់ជាតិនោះទេ គឺថាបើកាលណាទំនៀមទម្លាប់នោះល្អស្រួលហើយ ត្រូវតែប្រតិបត្តិឲ្យមានឋិតថេរតទៅ ប្រសិនបើទំនៀមទម្លាប់នោះមិនសូវស្រួលល្អទេ ត្រូវតែកែតម្រូវឲ្យបានស្រួលឡើង ។

វត្ថុដែលជាទីគោរពយ៉ាងធំសំខាន់បំផុតរបស់ជាតិយើងគឺព្រះពុទ្ធសាសនា ជាមតិកពីដូនតារបស់យើងទុកមក ដែលលោកប្រដៅប្តូនាន ញ៉ាំងចិត្តមនុស្សលោកឲ្យបានបរិសុទ្ធសុចរិតស្លូតត្រង់ជាបំផុតតាមតម្រារបស់ព្រះសម្មាសម្ពុទ្ធគោតម ។ ឯសេចក្តីប៉ុនប៉ងយ៉ាងមាំរបស់ខ្ញុំ គឺប៉ងឲ្យអាណាប្រជាពលរដ្ឋមានសេចក្តីព្យាយាមទស្សាហ៍ប្រតិបត្តិតាមសាសនាដែលបរិសុទ្ធវិសេសដូច្នេះ ។

ធម្មតាចិត្តមនុស្សមិនដែលបរិសុទ្ធល្អឯង ធម្មតាចំណង់មនុស្សមិនដែលមានព្យាយាមមាំមួនឯង ឬលុះទៅដោយការលះបង់ឯង។ ដែលនឹងធ្វើចិត្តឲ្យបរិសុទ្ធបាន ធ្វើចំណង់ឲ្យមានព្យាយាមមាំមួនឡើងបាន ឬឲ្យលុះទៅតាមការលះបង់បាននោះ ត្រូវឲ្យមានវេបុព្វកម្មឲ្យប្រតិបត្តិជាទួលាយស្រួល តែកុំបីឲ្យឃ្លាតពីសេចក្តីព្យាយាមសោះឡើយ ។ ឯវេបុព្វកម្មឲ្យប្រតិបត្តិនោះ គ្មានអ្នកណាអាចនឹងធ្វើឲ្យបានប្រសើរលើសអំពីវេបុព្វដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងក្រែមដើមអដ្ឋកថានិគ្រោធពោធិវង្ស ២៩០០ ឆ្នាំមកហើយនោះទេ ដែលព្រះអង្គទ្រង់ប្រកបដោយមហាករុណាដល់មនុស្សលោក ក៏ទ្រង់បានសំដែងទុកជាវេបុព្វនេះឲ្យបានបេះដ៏ងឡើង ។ សេចក្តីនេះ គឺទ្រង់រំឭកដល់អាណាប្រជាពលរដ្ឋខាំងឲ្យចំពោះឲ្យប្រតិបត្តិតាមទុកជាវេបុព្វរបស់ព្រះសម្មាសម្ពុទ្ធឲ្យបានត្រឹមត្រូវហ្មត់ចត់មាំមួនឡើង ។

សុំលោកអាម៉ីរ៉ាល់ជ្រាប! តែតាមន័យដូចមានអធិប្បាយខាងអម្បាលម៉ានខាងលើនេះហើយ ដែលខ្ញុំនឹងព្យាយាមជាស់តឿនអាណាប្រជាពស្តរបស់ខ្ញុំឲ្យប្រតិបត្តិតាម ។

ខ្ញុំមានព្រះពរជាប្អូនយ៉ាងគិតជួយអាណាប្រជាពស្តធ្វើឲ្យបានសំរេចតាមន័យដែលខ្ញុំបានអធិប្បាយរំឭកមកនេះ ដោយខ្ញុំត្រូវប្រតិបត្តិឲ្យខ្ជាប់ខ្ជួនតឹមត្រូវតាមការៈដែលខ្ញុំទួនមកដូច្នេះផង ។

ចំណែកខាងខ្ញុំដែលបានឡើងគ្រងពរសម្បត្តិនេះ គឺខ្ញុំទទួលការខុសត្រូវពេញខ្នាំងអស់តាមនាទីរបស់ខ្ញុំ ហើយខ្ញុំបានប្តេជ្ញាចិត្តសំរេចឲ្យបានស្រួលតាមកិច្ចមុខក្រសួងដែលគម្រាមកលើខ្ញុំជាអ្នកណែនាំឲ្យបានចំរើនតទៅ ។

ខ្ញុំមានសង្ឃឹមជាក់ថា មុខជានឹងមានទេវតាលើមេឃជួយជាកំឡាំងដល់ខ្ញុំ ដើម្បីឲ្យខ្ញុំចាត់ការរបស់ខ្ញុំបានសំរេចដូចសេចក្តីប្រាថ្នា ហើយថាអំពីដែលខ្ញុំនឹងតំរៀបចំនេះ នឹងបានសំរេចឲ្យកម្ពុជរដ្ឋបានរៀបថ្មីស្រួលឡើងទៅថ្ងៃមុខជាមិនខាន តាមព្រះពរជ័យណនៃព្រះគុណាព្រះបរមខត្តិយកោដ្ឋ ដែលខ្ញុំបានគិតរៀបចំដូច្នោះមកកាលទៅក្នុងបច្ចុប្បន្នវិយរបស់ខ្ញុំ ។

ខ្ញុំរំឭកដោយពេញឥទ្ធិដល់អស់ជនាទុជនទេមរជាតិ ឲ្យដឹកចិត្តលើកព្វសំណាងព្រះនគរតាមន័យដូច្នេះឯង ។

ព្រះរាជទិដ្ឋារន្ធរ៍ព្រះបន្ទូលស្តេរសីហនាទ

ខ្ញុំនខ្ញុំឯងនេះគឺ:

ព្រះបាទសម្តេចព្រះនរោត្តម - សីហនុ រ្ស៊ែន រាជហរីវង្ស ទ្រភោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរ័តន៍ នរោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះបៅក្រុងកម្ពុជាធិបតី ជាម្ចាស់ជីវិតលើត្បូង

ខណៈនេះខ្ញុំត្រូវការថ្លែងពណ៌ដ៏មានដូចមានខាងក្រោយចំពោះ

ដល់ព្រះកដវង្សានុវង្ស

ដល់សេនាបតី

ដល់អស់នាហ៊ុនសព្វមុខមន្ត្រី ក្រសួងផ្ទៃបាលទំនឹងក្រសួងតុលាការ ក្នុងក្រុងទំនឹងគ្រប់ខែត្រ

ដល់ជនានុជនក្នុងក្រុងពាល់ទីប្រជុំទំនឹងស្រុកស្រែចំការពាំងអស់ បួរបានដឹងការរៀងពាល់ចំណែក ។

ដ្បិតព្រះកដពិធីបុណ្យព្រះមេរុ នៃព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ-មុនីវង្ស ជាព្រះកដអយ្យកោនៃខ្ញុំ ព្រមទាំងពិធីជាកិសេកផ្ទាល់ខ្លួនខ្ញុំនេះ ក៏បានរៀបគាក់តែងធ្វើសរម្រេចដោយរុងរឿងយ៉ាងច្រើរតាមរបៀបរម្ងាប់ទំនឹងទំនៀមពីបុពណរៀងមកហើយ ។

ហេតុនេះ ខ្ញុំត្រូវការថ្លែងសេចក្តីសោមនស្សអរគុណដល់សប្បុរសទាំងឡាយ ពោះព្រះពជវង្សានុវង្សក្តី សេនាបតីក្តី នាហ្មឹងសព្វមុខមន្ត្រីក្តី ដែលបានទទួលទឿយហត់ដួយខំនុកបំរុងដោយស្មោះ ធ្វើឲ្យបានពិធីបុណ្យល្អរុងរឿងដល់ម្ល៉ះ ។

ខ្ញុំសូមអរគុណដល់ចំណែកព្រះសង្ឃ ដែលបានយកព្រះទ័យទុកដាក់ដ្រះថ្លានិមន្តមកដួយធ្វើឲ្យបានរុងរឿង ជាទីលើកសិរីសួស្តីក្នុងពិធីបុណ្យនេះផង ។

មួយយ៉ាងទៀត ខ្ញុំមានសេចក្តីសោមនស្សក្រែកយដោយបានឃើញអាណាប្រជាជនទាំងគ្នាចូលមកក្នុងទីតាសបុណ្យនេះជាច្រើនហើយឃើញប្រកបទូវៃរយោបថយ៉ាងសុភាពល្អ អាចជាបន្ទាល់ឲ្យឃើញថាមានចិត្តស្រឡាញ់ដល់ព្រះគុណព្រះបរមខត្តិយៈតាដ្ឋនោះផង ទំងមានសេចក្តីសប្បុរសស្មោះត្រង់ចំពោះដល់រូបខ្ញុំនេះថែមទៀត ។

មួយយ៉ាងទៀត ខ្ញុំមានអំណរណាស់ដោយមានទីតាសនេះដាល់-អានឲ្យខ្ញុំបានមកសន្ទនាផ្តាល់ដល់អស់ជនានុជនទាំងឡាយឲ្យបានយល់ភ្លឺ អំពីកិច្ចកម្មវិធីបាកដែលមានមកតាមសកពជកងសម័យនេះ ហើយទំងបានឲ្យសេចក្តីខ្ជូនខ្ជះដល់អាណាប្រជានុកស្តែផង ។

ខ្ញុំមានចិត្តជឿប្លាស់ថា អាណាប្រជានុកស្តែមុខជានឹងប្រតិបត្តិតាមសេចក្តីខ្ជូននេះ ហើយមុខជាទំងមានសេចក្តីជាម្ល៉ះ យកចិត្តទុកដាក់

ដល់ព្រះនគរខាងអនាគត ស្មើដូចជាប្រយោជន៍ផ្ទាល់ខ្លួន តាមសេចក្តីខ្ជួនខ្នានេះជាមិនខាន ។

ក - អំពីកិច្ចការឲ្យការពារអំណាចស្តេចជាតិ

អំពីកិច្ចដែលត្រូវឲ្យហ៊ានទទួលការខុសត្រូវលើអាត្មា

អំពីគ្រឹះគោរពប្រតិបត្តិ

សេចក្តីខ្ជួនាន ๑ អធិប្បាយអំពីរបៀបអំណាចនិងរបៀបកិច្ចការដែលត្រូវទទួលខុសត្រូវលើខ្លួន ។ មានមន្ត្រីជាច្រើនរូបដែលតែងតែបរិណ្តតបណ្តាយខាងតាមសេចក្តីពាយបាយ. ចេះតែមានគំនិតគិតពីងផ្អែកខាងលើអ្នកដំណាងនគរបាក់ងសែសឲ្យសម្រេចសេចក្តីផ្សេងៗដួសខ្លួនខាងក្រៅ ។ គំនិតដែលគិតខុសបែបនេះ អាចនាំបណ្តាលឲ្យមន្ត្រីពួកនោះឯងមានគំនិតខុសគិតរអែងខ្លាចមិនហ៊ានទទួលព័ប់ខុសត្រូវលើខ្លួនដោយស្មោះពេញចិត្តបណ្តាលឲ្យចេតនាទទួលស្គាល់សម្រេចកិច្ចការពាដការបានល្អិតល្អេពេញមុខគ្រប់ជ្រុងសោះឡើយ ។

ឯអំពើទាស់នេះ នាំឲ្យខូចខាតអាណាប្រយោជន៍នៃព្រះនគរហើយនាំឲ្យមាស់ខុសនឹងរបៀបលទ្ធិតស្សរគោពរបស់ពាដការអាណាព្យាបាលបាក់ងសែសនោះផង ឯពាដការអាណាព្យាបាលបាក់ងសែសមានក្រែថ្នាងដ៏ឲ្យមន្ត្រីខេមរជាតិ ចេះមានគំនិតដណ្តើម ចេះហាត់ចែងការពាដការឲ្យបានកើតមាំមួនឡើង ។

ខ្ញុំមានសេចក្តីសង្ឃឹមថា អំណោះតៅអ្នកចាំងអស់ជាដំណាងកជការផែនដីមុខជានឹងយកចិត្តទុកជាក់បំបាត់អំពើប្រព្រឹត្តខុសដូច្នេះចោលចេញហើយ។ថា អ្នកពជការគ្រប់ដំណែង មុខជានឹងចេញមុខសំរេចកិច្ចការពេញអំណាច ដែលខ្ញុំបានប្រគល់តៅឲ្យគាន់តាប់រឿងពាល់ចំណែកតៅ ដោយខ្លួនវិបានពាក់ព្រះមេត្រីនឹងជាមួយនឹងអ្នកវេស៊ីជនឹតជាតិបាំងសែសផងជាមិនខាន ។

មួយយ៉ាងទៀត ខ្ញុំសង្ឃឹមថាអាណាប្រជានុកស្តួដែលជាទីតាប់ចិត្តរបស់ខ្ញុំ មុខជានឹងដឹងស្គាល់នូវប្រយោជន៍ដែលគប្បីឲ្យគោរពគោតភ្ញាបតាមក្រឹត្យច្បាប់ដោយអហង្ការ ហើយមុខជានឹងនាំគ្នាយកចិត្តទុកជាក់ធ្វើកិច្ចគោរពច្បាប់នឹងទទួលស្គាប់បង្គាប់ជាចំផុតក្នុងពេលសម័យនេះ អាចទុកជាតម្រាប់ល្អតៅ ។

ខ - អំពីត្រូវឲ្យមានចេតនាយកចិត្តទុកជាក់ធ្វើការដោយឥតច្រឡំយកប្រយោជន៍ចំពោះខ្លួន នឹងអំពីសេចក្តីយកចិត្តទុកជាក់ស្មោះត្រង់ចំពោះព្រះនគរ ។

តំនិតគិតខុសមួយយ៉ាងទៀតរបស់ជាតិយើង គឺគ្មានចេតនានឹងយកចិត្តទុកជាក់ឲ្យបានស្មោះ បើធ្វើការរបស់អ្វីៗបំណងចង់តែឲ្យបានបំរើនតែតាមសេចក្តីត្រូវការជាប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ ឥតមានសង្ឃឹតចង់ឲ្យបានលើសតៅទៀតឡើយ ។

នៅស្រុកយើង មានមនុស្សចំពួកខ្លះមិនសូវជាគិតការផ្គាល់ខ្លួនពេកណាស់ទេ តែយកចិត្តទុកដាក់ចំពោះតែក្នុងវង្សត្រកូលរបស់ខ្លួន កាលបើមានទេមវាជាតិនីមួយៗប្រកបនូវសេចក្តីស្រឡាញ់នគរបស់ខ្លួនជាទីបំផុតចិត្ត ហើយមានបំណងប៉ងនឹងប្តូរដើរតែរបស់ខ្លួនស្មងជាប្រយោជន៍នគរបាន ប៉ុន្តែតាមធម្មតាអ្នកដែលមានសេចក្តីស្រឡាញ់ទឹងស្មោះត្រង់ដូច្នោះ ហើយរំយកចិត្តទុកដាក់ប្រឹតប្រឹងធ្វើការជាជាងនេះ តែមានច្បាស់ថាយកប្រយោជន៍ផ្គាល់ខ្លួនដូច្នោះ ក៏សោតសឹងមានតិចរូបណាស់ ។

ឯដោយពិតនោះ គឺមនុស្សនឹងត្រកូលត្រូវសំគាល់ថាយកកំណើតអាស្រ័យដោយមានស្រុកកំណើតដែលជាទីតាំងឲ្យខ្លួនមានបេះរកស៊ីនឹងឲ្យបានសេចក្តីសុខក្នុងការចិញ្ចឹមជីវិតរបស់ខ្លួន ។

សេចក្តីនេះ ខ្ញុំសុំកុំឲ្យទេមវាជាតិក្លេចឡើយ ហើយសុំឲ្យដឹងថាសិរីសួស្តីជយមង្គលថ្កើងថ្កានរបស់ប្រទេសនីមួយៗមិនសូវមានបណ្តាលកើតឡើងមកពីសេចក្តីក្លាហានរបស់មនុស្សត្រឹមតែប៉ុន្មាននាក់នោះទេ គឺច្រើនកើតមកពីសេចក្តីព្យាយាមព្រមទាំងការអត់ធន់របស់មនុស្សដែលរួបរួមច្រើនគ្នាទៀត ។

៤ - អំពីសេចក្តីរួបរួមសាមគ្គីនៃកម្ពុជវង្ស នឹងប្រទេសឥណ្ឌូស៊ីន ។

ព្រំប្រទល់នៃប្រទេសរបស់យើង មិនមែនជាទីជាំងខ័ណ្ឌមិនឲ្យយើងសំរេចកិច្ចការបានហួសទៅត្រើយនោះទេ គឺហួសពីទីព្រំប្រទល់នោះទៅ

មានប្រទេសធំៗទៀត ដែលកម្ពុជរដ្ឋបានរួបរួមសាមគ្គីជាប្រយោជន៍ផ្ទាល់ជាតិ ហើយមានចុះខសញ្ញាល័ក្ខខ័ណ្ឌជាគ្រឹមត្រូវតាមច្បាប់នោះផង ។

រឿងនេះគឺខ្ញុំចង់អធិប្បាយអំពីប្រទេសឥណ្ឌូស៊ីនជាដើមហេតុ ដែលដើមទ្បើយគ្រាន់តែជាទីប្រជុំអាណាចក្រមួយដែនជាមួយគ្នាប៉ុណ្ណោះទេ តែកន្លងរាងប៉ុន្មានឆ្នាំមុននេះបានចំរើនទ្បើងរួបរួមគ្នាជាសហរដ្ឋមួយយ៉ាងមាំមួន ។

គឺសេចក្តីចំរើនក្នុងការផ្លែដំនួញទៅវិញទៅមកច្រើនៗទ្បើងកាលថ្ងៃសេចក្តីមេត្រីកាន់តែមានគ្នាដោយដឹងស្គាល់ដល់មុខគ្នាទៅវិញទៅមក រឹងតែតែជ្រួតជ្រាបខ្លាំងទ្បើង ព្រមទាំងការទទួលបង្ហាតជាទម្ងន់ក្នុងកិច្ចការការពារទឹកដីជាមួយគ្នាកាលមុនមិញនេះទៀត នេះហើយដែលជាហេតុនាំឲ្យខេមរជាតិជាតិលាវនិងជាតិយួនបានរួបរួមគ្នាតទៅ ។

ខ្ញុំមានចិត្តចង់ឲ្យអាណាប្រជានុកស្គាំងក្ងេចសេចក្តីដែលធ្លាប់មានអធិករណៈទឹងគ្នាពីដើមមកនោះចោលទៅ ដើម្បីឲ្យពួកយើញតែអំពីសេចក្តីដែលទើបចងមិត្រមេត្រីទឹងគ្នាថ្មីៗនេះតទៅ ហើយត្រូវឲ្យជួយបត្តម្ភដល់សហរដ្ឋឥណ្ឌូស៊ីនតាមកំលាំងរបស់ខ្លួនផង កុំបីប្រថាំទឹងប្រទេសជិតខាងទ្បើយ ។

ឃ - អំពីការញុំាងកម្ពុជរដ្ឋឲ្យបានចំរើនឡើង ទាំងអំពីការធ្វើប្រទេស
ជាកំពង់សែសឲ្យបានរើរួចផុតពីសេចក្តីវុនវាយឡើងវិញ ។

ប្រទេសឥណ្ឌូស៊ីនេះគ្រាន់តែជាភាគ១នៃប្រទេសពជាកំពង់សែស
ប៉ុណ្ណោះទេ ហើយដែនកម្ពុជាដែលនៅក្នុងប្រជុំប្រទេសឥណ្ឌូស៊ីន ក៏ពប់
បូលក្នុងវង់ប្រទេសពជរបស់ជាកំពង់សែស ដែលមានទំហំដ៏ធំរួមប្រទេស
ជាច្រើននោះដែរ ក្នុងប្រទេសពជរបស់ជាកំពង់សែសទាំងមូលមានមនុស្ស
ចំនួន ១០០ លាននាក់ មានទំហំដីធំជាងដែនកម្ពុជាចំនួន ៥០ ដង ។

ខ្ញុំត្រូវរំឭកឲ្យយើញឡើងថា ដោយសារមានប្រទេសពជជាកំពង់
ធំនៅជាកំពុំាងដូច្នោះហើយ បានជាប្រទេសយើងមិនអាចរលាយទៅបាន
ហើយមួយវិញទៀត ដោយមានចាត់តាក្នុងប្រទេសពជនោះចេះតែចំរើន
ឡើង ។ នោះគង់មានថ្ងៃណាមួយប្រទេសយើងនឹងមានសិរីសួស្តីជ័យ-
មង្គលប្រែបានជាថ្កើងដូចកាលអំពីបុពណ៌ឡើងវិញពុំខាន ។

ដូច្នេះ ត្រែវអំពីសេចក្តីសាមគ្គីដែលត្រូវជួយឈឺឆ្អាលដល់សហរដ្ឋ
ឥណ្ឌូស៊ីន ដែលខ្ញុំទើបនឹងអធិប្បាយខាងលើនេះ ខ្ញុំសុំឲ្យអាណាប្រជាជន
ដ៏ឯយល់ឯយតាមកិច្ចធុរៈនៃប្រទេសពជនោះផង ។

សេចក្តីនេះ គួរអធិប្បាយឲ្យយើញឡើងថា មេត្រីភាពដែលកម្ពុជរដ្ឋ
ត្រូវសំដែងក៏ស្តាងឲ្យយើញជាក់ស្តែងចំពោះប្រទេសជាកំពង់សែសក្នុង

ប៉ុន្តែបច្ចុប្បន្ននេះ មិនមែនគ្រាន់តែប្រកបតាមទំនៀមទម្លាប់សុចរិតស្មោះត្រង់របស់ជាតិនេមរៈប៉ុណ្ណោះទេ គឺប្រកបតាមយោបល់ថ្មីដែលឈ្វេងយល់ដល់អាណាប្រយោជន៍ជីវិតធ្លាយរបស់ប្រទេសនេះផង ។

កម្ពុជរដ្ឋសព្វថ្ងៃ បើទុកជាស្រពោនស្រពាប់សូប់សូតដូចម្តេចក្តី ដោយហេតុដែលទើបមានបណ្តាលមកថ្មីៗនេះ ក៏គេមិនមែនបដិសេធទុកឲ្យនៅតែឯកឯងឯកឆ្ងាយលោកនេះទេ គឺថាបើប្រទេសជាកំឆែសសនៅជួយទំនុកបំរុងគ្នាទៅទៀត នេះមុខជាទំនាក់ទំនងវង្សជាអង្គឯងមិនខាន ។ មានតែហេតុដោយឡែកប៉ុណ្ណោះទេ ដែលបណ្តាលនាំឲ្យប្រទេសជាកំឆែសអន់ថយកំឡាំងកន្លះ ១ ខណៈនេះ តែត្រូវសង្ឃឹមថាកន្លះពេលទៅមុខគង់ទំនាក់ទំនងជាន់ស្រួលឡើងវិញ នាំឲ្យប្រទេសអាណាព្យាបាលបានរើរួចទៅការងារសេចក្តីវុឌ្ឍរឿង ហើយប្រទេសយើងក៏ទំនាក់ទំនងរៀបចំល្អឡើងវិញដែរ ។

ង - អំពីសេចក្តីគោរពព្រះពុទ្ធសាសនា

ខ្ញុំមិនមែនមានបំណងអធិប្បាយតែអំពីកិច្ចការដែលមានប្រយោជន៍ចំពោះភ័ព្វសំណាងនៃប្រទេសយើងប៉ុណ្ណោះ ហើយឥតអធិប្បាយអំពីទំនៀមទម្លាប់របស់ជាតិនោះទេ គឺថាបើកាលណាទំនៀមទម្លាប់នោះល្អត្រូវតែប្រតិបត្តិឲ្យតង់នៅបឋមវេតទៅ ។

រីឯដែលជាទំនោរពយ៉ាងធំសំខាន់បំផុតរបស់ជាតិយើងគឺព្រះពុទ្ធសាសនា ជាមរដកពីដូនតារបស់យើងទុកមក ដែលលោកអាចប្រដៅ

ខ្ញុំនានញ៉ាំងចិត្តមនុស្សលោកឲ្យបានចរិសុទ្ធសុចរិតស្មូតត្រង់ជាបំផុត តាមតម្រាប់នៃព្រះគោតមបរមសម្មាសម្ពុទ្ធ ។

ឯបំណងយ៉ាងមាំរបស់ខ្ញុំ ចង់ឲ្យអាណាប្រជានុកស្តីមានសេចក្តីព្យាយាមនុសាហ៍បដិបត្តិតាមសាសនាដ៏បរិសុទ្ធដ៏វិសេសនេះ ។

ខ្ញុំចង់ឲ្យអាណាប្រជាជនទាំងអស់ ទោះជាបព្វជិតក្តី គ្រហស្ថក្តី បដិបត្តិឲ្យខ្ជៀងខាត់ត្រឹមត្រូវតាមពុទ្ធប្បញ្ញត្តិ ដើម្បីឲ្យកម្ពុជរដ្ឋយើងដែលបានគ្រប់គ្រងរក្សាបែបបទនៃសាសនាដ៏បរិសុទ្ធឲ្យបិតថេរគង់ត្រង់ជាច្រើនសតវត្សមកហើយនោះ បាននៅជាគំរូបែរសើរលើសជាងនានាប្រទេសដែលកាន់ព្រះពុទ្ធសាសនាដូចគ្នានៅបុរាណបូពាប្រទេស ។

ច - អំពីការដែលត្រូវសិក្សា

អំពីការដែលឲ្យប្រព្រឹត្តកាន់សាសនាឲ្យខ្ជៀងខាត់នោះ មិនមែនជាហេតុបណ្តាលឲ្យពួកអ្នកមានសតិបញ្ញាអាក់ខានក្នុងការរៀនសូត្រវិជ្ជាដ្បូងឡើយ ខ្ញុំចង់ឲ្យពួកខ្មែរជនដែលមានសតិបញ្ញាច្រើនទំរឹងប្រែងប្រែងខ្លៅងកុំដឹងខ្ជិនខ្ជន់ឡើយ ណាយន៍ការរៀនសូត្រវិជ្ជាបែកខាងបច្ចុប្បន្នប្រទេសខ្លៅយ គឺឲ្យយកចិត្តទុកដាក់ទិតទំរៀនសូត្រសិល្បសាស្ត្រសម័យថ្មីឲ្យមាំមួនខ្លៅង ។

ការដែលរៀនសូត្រសិល្បសាស្ត្រសម័យថ្មីនេះ ពុំមែនគ្រាន់តែបានបំណេះវិជ្ជាឲ្យផលប្រយោជន៍ក្នុងការទៀបហាត់ប៉ុណ្ណោះទេ គឺជាបច្ច័យឲ្យបានត្តើមុខក្នុងការធ្វើប្រយោជន៍ឲ្យប្រទេសរបស់ខ្លួនថែមទៀតផង ។

សព្វថ្ងៃនេះ មានទីដំណែងដ៏សំខាន់ៗជាច្រើនកន្លែងនៅលើផែដាតគាង ប្រទេស ឯកន្លែងទាំងនោះគួរនឹងប្រគល់ទុកជាក់ឲ្យខ្មែរជាតិកាន់កាប់បាន ដូចយ៉ាងមុខក្រសួងវិស្វកម្ម គ្រូបង្រៀនជាន់ខ្ពស់ នឹងគ្រូពេទ្យជាដើម ។

ឯការផែលខ្វះមនុស្សជាតិខ្មែរកាន់កាប់ទីដំណែងដ៏សំខាន់ៗដូច្នោះពិតមែនតែកន្លែងដំណែងខ្វះមិនសូវជាបណ្តាលឲ្យបង្កាគប្រយោជន៍ប៉ុន្មានទេ ប៉ុន្តែមានដំណែងខ្វះបណ្តាលឲ្យខូចទាគប្រយោជន៍យ៉ាងធំបំផុត ។

សេចក្តីនេះ ខ្ញុំចង់លើកគួយ៉ាងឲ្យយើញឡើងអំពីការផែលខ្វះគ្រូអោយខ្មែរជាតិធ្វើការ បណ្តាលឲ្យខូចរបៀបចាត់ការនៃក្រសួងព្យាបាលពេទ្យផែលការពារមនុស្សមិនឲ្យមានឈឺចាប់ស្លាប់ច្រើន ហើយមិនអាចនឹងជួយសង្គ្រោះឲ្យមានមនុស្សកើតច្រើនតាមសេចក្តីត្រូវការជាប្រយោជន៍ប្រទេសនោះផង ។

ខ្ញុំមានសង្ឃឹមថា ពួកយុវជនក្នុងប្រទេសយើងមុខជានឹងប្រតិបត្តិតាមដំបូន្មានរបស់ខ្ញុំមិនខាន ហើយអំណោះតទៅមុខជានឹងខិតខំប្រឹងរៀនសូត្រដណ្តើមយកថ្នាំដៃក្នុងសាលាជាប្រាកដ ។

ពួកយុវជនទាំងនោះមុខជានឹងខំរៀនប្រឡងយកសញ្ញាប័ត្រឲ្យបានដើម្បីឲ្យយើញថាខ្មែរជាតិមិនមែនគ្រាន់តែមានដំឡៃខ្ពស់លើសគេ

ដោយសារតែមានសេចក្តីសុភាពសុចរិតស្លូតត្រង់ប៉ុណ្ណោះទេ ទាំងសេចក្តីវៃឆ្លាតក៏ខ្ពស់ជាជាងបងប្អូនៗដែរ ។

ឆ - ជំពូនានដោយប្រុងប្រយ័ត្ន ។

ខ្ញុំខើបនឹងអធិប្បាយរឿងធំៗមកអម្បាញ់មិញនេះ ដោយមានបំណងចង់ឲ្យអាណាប្រជាជនបេស់ខ្ញុំយកចិត្តទុកដាក់ប្រតិបត្តិតាម ។ ក្រៅពីរឿងទាំងនោះនៅមានរឿងពីរទៀតដែលខ្ញុំមិនចង់បំភ្លេចចោលទេ្លយ គឺចរិយាល្អសព្វថ្ងៃនេះឯង ដែលនាំឲ្យជនានុជនអាចប្រស្រ័យគ្នាបានដោយងាយ ហើយជួយឲ្យមានសាមគ្គីធម៌ដល់គ្នានឹងគ្នា ជាប្រយោជន៍ឲ្យបានសុខក្សេមក្សាន្តរាល់រូប ។

ភាសាបាលីមានស័ព្ទបែកច្រើន សំរាប់សំគាល់ចរិយាផ្សេងៗហើយពួកខេមរបុត្រទាំងឡាយក៏បានរៀនចេះដឹងតាមស័ព្ទទាំងពីនៅជាកុមារតូចៗនៅទេ្លយ ចរិយា ៤ យ៉ាងគឺ:

មេត្តា សេចក្តីពាប់អានស្រឡាញ់គ្នា ករុណា សេចក្តីអាណិតអាសូរគ្នា មុទិតា សេចក្តីរីករាយចំពោះសេចក្តីសុខ-ចំរើនរបស់អ្នកដទៃ ឧបេក្ខា សេចក្តីតាំងចិត្តជាកណ្តាល មិនលំអៀងទៅខាងណា ។

រួមធម្មចរិយាទាំងនេះជាគតិដែលខេមរជាតិតែងនិយមយកពាប់អាន ហើយទាំងឲ្យជនជាតិដទៃយកមកប្រាវឌ្ឍដំណាលសរសើរជាការគោរពល្អនឹងស្លូតត្រង់ស្មើមុខ ។

បំណងដ៏ស្មោះរបស់ខ្ញុំ ។ បងធំឲ្យជនាខុជនក្នុងកម្ពុជរដ្ឋនៅតែប្រតិបត្តិ
តាមធម្មចរិយាព្រហ្មវិហារធំនេះ ឲ្យបានខៀងចាត់តែមតែរតាមប្រ-
វេណីតទៅ ដូចកាលដូនតាពីដើមរៀងមក ហើយឲ្យរៀកុំឲ្យមានគំនិត
គិតវិវាទដល់គ្នានឹងគ្នា ។

រីឯចាំងនេះហើយដែលខ្ញុំប៉ងនឹងថ្វាយឲ្យបានព្រះដល់អាណាប្រជា-
ទុកស្តេរបស់ខ្ញុំ ។ ដំបូន្មាននេះជាការជោរាទថ្វាយប្រដៅចំពោះអាណាប្រជា-
ទុកស្តេដែលជាតិតាប់ព្រះពុទ្ធហ្វូយ៉ៃក្រៃពេក សុំឲ្យអស់អាណាប្រជាជន
យល់តាមពាក្យខ្ញុំន្មានចាំងនេះឲ្យជាក់ច្បាស់ ហើយឲ្យយល់ថាមកពីខ្ញុំ
មានមេត្រីយ៉ាងស្មោះ ទើបបណ្តាលឲ្យខ្ញុំថ្វាយទុក្ខដូច្នេះ ។ តែធម្មតា
ក្សត្រនីមួយៗមិនមែនតែងតែត្រូវឲ្យទុក្ខដល់ប្រជាជនប៉ុណ្ណោះទេ តែត្រូវ
ប្រតិបត្តិព្រះអង្គឯងធ្វើឲ្យអាណាប្រជាទុកស្តេក្នុងព្រះពុទ្ធអាណាចក្របាន
សមេចប្រយោជន៍នោះផង ។ ចំណែកខាងខ្ញុំវិញក៏នឹងប្រតិបត្តិឲ្យត្រឹមត្រូវ
តាមកិច្ចការរបស់ខ្ញុំជាក្សត្រដោយទូរស្មោះត្រង់ តាមព្រះពុទ្ធសាសនាផង
គោរពតាមទំនៀមទម្លាប់ដ៏ប្រពៃរបស់ជាតិយើងផង ។

កាលបើខ្ញុំព្រមទាំងប្រជាជនបានប្រតិបត្តិត្រឹមត្រូវដូច្នេះ ពពួក
ទេវតាតែងតែជួយ តងនឹងជួយអភិបាលក្សត្រកម្ពុជសម្បត្តិរបស់ខ្ញុំ ឲ្យមាន

សិរីសួស្តីជយមង្គល ព្រមទាំងជួយបីបាច់រក្សាកម្ពុជរដ្ឋឲ្យបានថ្កុំថ្កើនរុងរឿង ជួយចំនុកបំពុងផ្ដង ផ្តើមប្រជាជនអ្នកមានជម្ងៃរបស់ខ្ញុំឲ្យបានប្រកបដោយសេចក្តីសុខក្សេមក្សាន្តនឹងសេចក្តីចំរើនឥតអាក់តរៀងទៅ ។

ព្រះរាជឧត្តារឲ្យព្រះបន្ទូលសួរសីហនាទ ធ្វើក្នុងព្រះបរមរាជវាំងក្រុងភ្នំពេញចតុមុខ នៅថ្ងៃសៅរ៍ ១២ កេីតខែកត្តិកឆ្នាំម្សាញ់ត្រីស័ក ព្រះពុទ្ធសករាជ ២៤៨៤ ត្រូវនឹងថ្ងៃ ១ ខែណូវែមប្រ៊ីឆ្នាំ ១៩៤១ ។

នរោត្តម-សីហនុ ភ្ឈឹង

ចប់ព្រះរាជតិធីកថាកិសែកនៃប៉ុណ្ណោះ ។

ប្រវត្តិទង់ប្រចាំជាតិខ្មែរ

ឧកញ៉ា ទេពពិទូរ ក្រៃសេន

កាល ។ ជាតិកន្លងលោកនេះ ដែលមានៈសេចក្តីចំរើនរុងរឿងហើយ រមែងមានទង់ប្រចាំជាតិពាំងអស់ ប្លែកតែប្រើពណ៌ផ្សេង ។ ធ្លាស់គ្នាប៉ុណ្ណោះ ដោយជាគ្រឿងសំគាល់ជាតិ សាសនា មហាក្សត្រិយ៍ ទឹងអធិបតេយ្យ (តាវៈជាធំ) ជាដើមរបស់គេ, កន្លងពណ៌នីមួយ ។ ដែលយកមកប្រកបជាអគ្គទង់ឡើង សុទ្ធតែមានប្រវត្តិរបស់គេ អធិប្បាយហេតុផលទុកឲ្យយល់ផង មិនមែនចេះតែចាប់ជាក់ ។ ទៅតាមទំនើងចិត្តនោះទេ តែនឹងកំណត់ឲ្យជាការទៀងទាត់ថា ពណ៌ប៉ែបនេះ ជាគ្រឿងសំគាល់យ៉ាងនោះ ឲ្យត្រូវត្រង់គ្នាពាំងអស់ពុំបាន ព្រោះស្រែចហើយតែសេចក្តីត្រូវការ ពោលគឺប្រព្រឹត្តទៅតាមសេចក្តីនិយមរបស់អ្នកដើមការបញ្ញត្តឡើង ឬដោយអាស្រ័យមានហេតុកេរឯណា ទីមួយជាសំខាន់ដ៏ជាក់ជាមដោយពណ៌នោះកើតឡើងក្នុងស្រុកទេសរបស់នោះ គេក៏សន្មតយកពណ៌នោះទុកជាពណ៌ទង់ជាតិរបស់គេមួយយ៉ាង តែតោងរៀងធ្លាស់គ្នាដោយពណ៌ផ្សេង ។ ខ្លះទៀត យ៉ាងតិចត្រឹម ៣ ពណ៌ ។ តាមសេចក្តីនិយមដោយច្រើន ពណ៌សជាគ្រឿងសំគាល់សាសនា, ពណ៌ក្រហមជាគ្រឿងសំគាល់ជាតិមហាក្សត្រ, ពណ៌ខៀវផ្លែមេយ ជាគ្រឿងសំគាល់អធិបតេយ្យ ។

តែសម្រាប់ប្រទេសឥណ្ឌាក្នុងសម័យបុរាណ គាត់កំណត់ប្រើពាក្យ ឬពាក្យគ្រឹងសំលៀកបំពាក់របស់គេ ឃើញដូចជាមានរបៀបបែបផែនខ្ពង់ខ្ពាស់ណាស់ ព្រោះគេមានគ្រូ ឬមានតម្រាតែមួយបែប គួរយ៉ាងដូចវណ្ណៈ (ប្រភេទមនុស្ស) ៤ ចំពួកក្នុងប្រទេសឥណ្ឌា គេបញ្ញត្តពាក្យសម្រាប់វណ្ណៈនោះៗ ជាការខ្ពង់ខ្ពាស់រហូតមក គឺក្សត្រជាតិអ្នកបម្រុងពាក្យក្រហម, ព្រាហ្មណ៍អ្នកកាន់សាសនាពាក្យស, វៃស: ពួកអ្នកធ្វើការរកស៊ីជាធម្មតាពាក្យលឿង, សូទ្រ:ពួកកម្មករពាក្យខ្មៅ ។

ចំណែកខ្មែរយើង ក៏ជាមនុស្សជាតិដែលមានអារ្យធម៌ដ៏ខ្ពង់ខ្ពាស់ដោយអារ្យធម៌ឥណ្ឌាយ៉ាងច្រើន ហេតុនោះការដែលប្រើពាក្យខ្ពង់ខ្ពាស់ ឬពាក្យគ្រឹងសំលៀកបំពាក់ពាក្យច្រើនន័យមៅតាមបែបឥណ្ឌា គួរយ៉ាងដូចពាក្យខ្ពង់ជាតិនិងពាក្យសម្រាប់ព្រះមហាក្សត្រជាដើម ។

ឯខ្ពង់ជាតិខ្មែរអំពីដើមតាមផ្លូវសន្និដ្ឋានយើញថាជាពាក្យវៃត្តគ្គ (៣ ពាក្យ) គឺ

១ ពាក្យស ជាថ្នូ កង ៤ ជ្រុងត្រង់

២ ពាក្យក្រហម អមដុំវិញពាក្យស ទំង-

៣ ពាក្យថ្នូមេឃ អមដុំវិញពាក្យក្រហម បែបជាជាយ ។

អធិប្បាយ: តាមឈ្មោះបថកង់សាសនាព្រាហ្មណ៍ ដែលជាសាសនាចាស់ជាង់គេកង់លោក ហើយដែលខ្មែរយើងជាប់គាន់មកកង់សម័យព្រៃង

នាយនោះ និយមព័ណ៌ស ដែលជាព័ណ៌បរិសុទ្ធ ជាព័ណ៌សម្រាប់សាសនា ចូរមើលពួកព្រាហ្មណ៍អ្នកកាន់សាសនាវែងស្ងៀកពាក់សជាគ្រឿងសំគាល់ ។ ចំណែកខាងព្រះពុទ្ធសាសនា ឃើញដូចជានិយមព័ណ៌សតាមទំនងនេះខ្លះដែរ ចូរមើលពួកឧបាសកឧបាសិកាអ្នកដែលកាន់ម៉ឺងម៉ាត់ ក៏និយមស្ងៀកសពាក់សដោយច្រើន រៀវលែងតែពួកបព្វជិតគោងប្រើព័ណ៌លឿង ដោយអំណាចពុទ្ធប្បញ្ញត្តិនិណាដោយឡែកផ្សេង ។ ដោយហេតុនេះខ្ញុំរយើងគាលទំនងថ្មើមធ្វើទង់សម្រាប់ជាតំឡើងក៏បានលៃលកបញ្ញត្តយកតាមទំនងនេះ គឺទង់បែបដើមមុនសម័យនគរធំជាកុំព័ណ៌សជាហាន ជាគ្រឿងប្រកាសថាជាអ្នកកាន់សាសនា ដែលប្រៀបដោយជួនចិត្តដ៏បរិសុទ្ធ សឹងតាំងនៅកណ្តាលរូបកាយ តែលុះមកដល់សម័យក្រុងយសោធរបុរៈ (នគរធំ) ក្នុងរវាងពុទ្ធសករាជ ១.៤០០ ដល់ ១.៧០០ ដែលកើតប្រាសាទថ្មធំៗសឹងល្អអស្ចារ្យក្នុងលោកនេះឡើង ក៏កែប្រែទង់ជាតិដើម្បីទទួលកិត្តិយសថ្មីនោះ ដោយជាតព័ណ៌សចេញពុកតែព័ណ៌ក្រហមនឹងព័ណ៌ខៀវផ្ទៃមេឃ ហើយរៀបជាត់ព័ណ៌ក្រហមជាផ្ទៃព័ណ៌ខៀវផ្ទៃមេឃជាជាយជុំវិញ ហើយជាត់រូបប្រាសាទ (កំពូល ៣) ព័ណ៌សជាដំនួសត្រង់កណ្តាល គឺជាត់សង្កត់លើផ្ទៃក្រហមនោះ កាលមើលទៅក៏ឃើញហាក់ដូចជាព័ណ៌ត្រៃរង្គដូចដើម ។

ឯព័ណ៌ត្រហមជាគ្រឿងសំគាល់ព្រះមហាក្សត្រដែលជាអ្នកសុរាជាតិ
ទំនងជាអ្នកចម្បាំង សំដីមានអាការៈប្រៀបដូចសុរិយាវង្ស ឬប្រៀបដូចលោ-
ហិតរបស់វីរបុរសអ្នកក្លាហាន ។ តាមគតិស្តេចសៀមក្នុងជំពូកក្រឹត្យនេះ
មានព្រះភុទ្ធយ៉ាតហ្វា ជាដើម បានតំណត់យកព័ណ៌លឿងជាព័ណ៌ប្រចាំ
ព្រះបរមេកដវង្ស[1] (ខ្ញុំយើងមានកាន់យកតាមបែបនេះខ្លះដដែរ) ។

ចំណែកឯព័ណ៌ផ្ទៃមេឃ ជាគ្រឿងសំគាល់អធិបតេយ្យដែលធំខ្ពស់
គួបលើពិភពផែនដី ។ តែមកដល់សម័យមួយក្នុងរដ្ឋកាលព្រះបាទ
សិន្ធពអមរិន្ទ្រ បានកែប្រែទង់ជាតិម្តងដោយផ្ទាស់រូបច័ន្ទាសាទចេញ ដាក់
រូបសេះសដំនួស ព្រោះក្នុងរដ្ឋកាលនោះ ទង់និយមសេះសណាស់
លុះផុតរដ្ឋកាលនោះហើយ រដ្ឋកាលក្រោយមក បានត្រឡប់ផ្ទាស់រូប
សេះសចេញ ដាក់រូបច័ន្ទាសាទដូចដើមវិញ នៅរហូតមកដល់សព្វថ្ងៃ
នេះ ។ ព័ណ៌ទង់ខ្មៅនេះកាប់ថាត្រូវតាមលក្ខណៈព័ណ៌ដែលលោកនិយម
ល្អណាស់ ។

ទង់មហាកាឌ

ជាទង់សម្រាប់អង្គព្រះមហាក្សត្រម្ចាស់ផែនដី

ទង់សម្រាប់មហាក្សត្រម្ចាស់ផែនដី ហៅថា "ទង់មហាកាឌ"

---

(១) ចូរមើលសៀវភៅសិល្បការភោគ ១ ផ្នែកទី ២ ព.ស. ២៤៨១ ក្នុងរឿង "ត្រឿងសំ-
គាល់អាយ៉ណាយោស" ។

ទង់នេះមានលក្ខណៈខុសគ្នាទង់ជាតិដែលពោលហើយ គឺផ្ទៃជាព័ណ៌ផ្ទៃមេឃ ជាយជុំវិញជាព័ណ៌ក្រហម សំរង់ផ្តុំយគ្នាទំនងពណ៌ទង់ជាតិ, ត្រង់កណ្តាលផ្ទៃប៉ាក់ព័ណ៌មាស ជារូបព្រះខ័នដំកល់លើដើមពាន រូបព្រះមហាមកុដជាក់ពីលើព្រះខ័ន ហើយមានរូបធម្មចក្រ ១ គូ អមសងខាង ។ បើនឹងរួមកប់ព័ណ៌ទាំងអស់ទៅ ឃើញថាមានព័ណ៌ ៣ដែរ គឺព័ណ៌មាស ព័ណ៌ផ្ទៃមេឃ ព័ណ៌ក្រហម ខុសជាវែកន្តែងដូចដើម គ្រាន់តែឆ្ងាស់ព័ណ៌ខុសគ្នាប៉ុណ្ណោះ ។

ទង់មហាពជនេះ ប្រើបានចំពោះតែព្រះមហាក្សត្រម្ចាស់ផែនដី, តាមប្រក្រតី ត្រូវបង្ហុតទៅជាទង់ធំទៅមុខព្រះបរមពជរាំង នឹងប្រាសាទដែលស្តេចគង់ជាធម្មតាទៅក្នុងព្រះបរមពជរាំង, បើមានការត្រូវស្តេចទៅគង់ទៅដំណាក់-រាំងឯណា ន័មួយក្រៅពីព្រះបរមពជរាំង តាំងពី ២៤ ម៉ោងទៅ ត្រូវបង្ហុតទង់មហាពជទៅដំណាក់ឬរាំងនោះដែរ ជាគ្រឿងសំគាល់ថាស្តេចគង់នៅទីនោះ ។ ឬមួយកាលស្តេចគង់ព្រះពជរថទៅគាន់ទីដិតឬឆ្ងាយក៏ដោយ ត្រូវប្រដាប់ទង់មហាពជខ្នាតតូចទៅព្រះពជរថនោះជាគ្រឿងសំគាល់ថា ស្តេចគង់នៅក្នុងព្រះពជរថនោះ ឬថា អ្នកដែលអង្គុយនៅក្នុងព្រះពជរថនោះគឺព្រះពជាម្ចាស់ផែនដី អ្នកនៅជិតខាងត្រូវសំដែងសេចក្តីគោរពតាមសមគួរ ។

ទង់ជ័យ

ជាទង់សម្រាប់ទាហានសឹក

ទង់សម្រាប់ស្តេចសឹក មេទ័ព មេកង ប្រើក្នុងកងកងសង្គ្រាម ហៅថា "ទង់ជ័យ" មានលក្ខណៈផ្សេងពីទង់ពីរបែបខាងលើនេះខ្លះ ដូចអធិប្បាយតទៅនេះ:

តាមបែបបុរាណ បើជាទង់ជ័យសម្រាប់ព្រះមហាក្សត្រម្ចាស់ផែនដី សឹងគ្រប់ដណ្តើងជាស្តេចសឹក (ចមពល) ដោយព្រះអង្គឯង នោះរូបទង់ក៏ដូចជាទង់មហាពដែលពោលហើយ ប្លែកតែនៅចុងដងទង់ធ្វាក់ជារូបព្រះនាគយណ៍ទង់គ្រឹះ, (គឺព្រះនាគយណ៍គង់លើគ្រឹះ) តុំនោះសោតនៅត្រង់កណ្តាលផ្ទៃទង់ ប៉ាក់ដោយសូត្រព័ណ៌មាសជារូបព្រះនាគយណ៍ទង់គ្រឹះ ជាជំនួសរូបព្រះខ័ន ព្រះមហាមកុដ, តាមរឿងជាយដុំវិញប្រដាប់ដោយត្រួយរំយោលដែលធ្វើអំពីសូត្រព័ណ៌ដ៏វិចិត្រ ។

អ្នកឯទៀត (ក្រៅអំពីព្រះរាជា) ដូចយ៉ាងសម្តេចព្រះមហាឧបរាជាដើម បើទទួលដំណែងជាស្តេចសឹកធំ គាន់តាប់ទ័ពហ្លួង (ទ័ពធំ) ជំនួសព្រះរាជាម្ចាស់ផែនដី នោះនឹងប្រើទង់បែបនេះបាន, ក្រៅអំពីស្តេចសឹកចមទ័ពប្រើមិនបានទេ ។

ចំណែកទង់ជ័យសម្រាប់មេទ័ព មេកង រង់ស្តេចសឹកចុះមក មានលក្ខណៈប្រហែលទង់ទង់ជាតិនោះឯង ប្លែកតែនៅចុងដងទង់ធ្វាក់ជារូប

ហនុមានហោះ ពុំនោះសោតនៅកណ្តាលផ្ទៃទង់ ចាក់ដោយសូត្រ ព័ណ៌ស ជារូបហនុមានហោះ (គ្មានរូបច្បាសាទ) នៅរមែងដាយដុំវិញ ប្រដាប់ដោយព្រួយរំយោលយ៉ាងវិចិត្រ ។

តែបើសង្កេតមើលទង់ជ័យកងកងទ័ពរបស់ព្រះចៅទសូរ្យវ័ន មហាកដទី ២ ដែលធ្លាក់ទុកនៅព្រះរបៀងច្បាសាទនគរវត្ត ឃើញថាទង់ជ័យគ្រានោះគ្មានតួទង់មានតែដង ហើយទង់រូបព្រះនាគយណ៍ទង់គ្រុឌ រូបហនុមានហោះនៅចុងដងទង់ប៉ុណ្ណោះ ក្នុងសៀវភៅនិពន្ធសមគរវត្តរបស់សម្តេចព្រះយ៉ាងាំរង៉ែកជានុភាព ហៅទង់នេះថា កបិធ្វជ, គ្រុឌភាហ៍ គឺទង់រូបហនុមាន ហៅថា កបិធ្វជ, ទង់រូបព្រះនាគយណ៍ទង់គ្រុឌ ហៅថា គ្រុឌភាហ៍ សម្រាប់ប្រើនាំទ័ពកងកដការសង្គ្រាម គឺជាទង់ជ័យនាំទ័ពនោះឯង ។

ការគោរពទង់ជាតិ

ជាតិដែលមានអារ្យធម៌ មានសីលធម៌ សូម្បីជាជាតិតូច មិនសូវមានឥទ្ធិពល ក៏រមែងមានទង់ជាតិជាគ្រឿងសំគាល់ជាតិរបស់ខ្លួន កាលបើដូច្នេះ ទង់ជាតិក៏ទៅជារបស់ស័ក្តិសិទ្ធិមួយយ៉ាង ក្នុងបទដ្ឋានៃលោកថាប្រជាជនអ្នកនៅក្រោមម្លប់ទង់ជាតិនោះ ត្រូវសំដែងសេចក្តីគោរពតាម

សមគួរដល់ហានៈរបស់ខ្លួន គឺជាភាហានត្រូវគោរពតាមបែបភាហាន ពស្ត្រ
សាមញ្ញត្រូវគោរពតាមបែបពស្ត្រសាមញ្ញ, មិនត្រូវចោះបង់ចោលផ្តេស
ផ្តាស មិនត្រូវដើរកន្ទុង ដើរជាន់ញីញាក់ មិនត្រូវយកទៅជូតឬខ្ចប់អ្វីៗលៗ
កាលចាស់មិនត្រូវការប្រើហើយ ត្រូវទំលាយចោល ដោយដុតភ្លើង
ចោលជាដើម មិនត្រូវចោលពត់ពយក្នុងទីនីមួយឡើយ ។ អាការដែល
ពោលមកនេះឈ្មោះថាគោរពធម៌ជាតិ, អ្នកដែលមិនគោរពធម៌ជាតិ ទុក
ជាមនុស្សមិនស្រឡាញ់ជាតិ, អាការដែលធ្វើឲ្យឃើញជាក់ស្តែងនៅ
ចំមុខប្រជុំជន ត្រូវមានទោសក្នុងស្ថានណាមួយ ។

ប្រៃត្តិទង់ប្រចាំជាតិខ្មែរចប់តែប៉ុណ្ណេះ ។

អំពីអក្សរសាស្ត្រខ្មែរ

លោកសីនែសរៀបរៀង (តមកទំនឹងចប់)

តាមដោយពិត ហេតុដែលនាំឲ្យប្រែប្រួលចំពោះអក្សរសាស្ត្រខ្មែរ មានដូចគ្នានឹងហេតុដែលនាំឲ្យប្រែប្រួលនៃអារ្យធម៌ខ្មែរនោះដែរ អារ្យធម៌ខ្មែរដែលមានឥទ្ធិពលក្នុងសតវត្សរ៍ទី ១៣ និង ១៤ (ព.ស. ១៧៩០ ដល់ ១៩៥០) ទៅគ្របលើជាតិថៃនៅប្រទេសសៀមនឹងប្រទេសលាវយ៉ាងមាំមួន ។ ក្នុងខណៈនោះ អក្សរសាស្ត្រខ្មែរឈប់ចំរើននៅប្រទេសខ្មែរ អក្សរសាស្ត្រនោះទៅចំរើនខ្លាប់ខ្ជួននៅប្រទេសសៀមវិញ ។ ក្នុងសម័យថ្មីនេះគឺក្នុងដើមសតវត្សរ៍ទី ១៩ (ព.ស.២៣៩៣) អំណាចរបស់សៀមគ្របលើប្រទេសខ្មែរ សៀមក៏សង់មកប្រទេសខ្មែរវិញ ដោយកែប្រែផ្លាស់ប្តូរចេញចំពោះការងារដែលប្រទេសសៀមបានទទួលយកទៅតាលពីសតវត្សរ៍ទី ១៣ ដោយហេតុនេះ ទើបលំបាកនឹងពិនិត្យរំលែកក្នុងអក្សរសាស្ត្រខ្មែរ ចែកចេញឲ្យឃើញថានេះជាប្រៈវណីរបស់ខ្មែរតៗមកដោយត្រង់ៗ នេះជាទំនៀមប្រៈវណីដែលប្រែប្រួលហើយត្រឡប់មកអំពីប្រទេសសៀមមកវិញ នេះជាបែបផែនដែលមកអំពីឥទ្ធិពលរបស់តាងប្រទេសដ៏ពិតៗ ។ ការវុកវរយ៉ាងនេះ ពិបាកនឹងរកឲ្យបានច្បាស់ល្អ ហើយថែមទាំងពោលដោយពិត ឃើញថាមិនជាមានប្រយោជន៍ដ៏ធំដុំទេ ទាំងសាច់រឿងសោតទៀតក៏មិនជាការសំខាន់ប៉ុន្មាន ។ ការកសាងអក្សរសាស្ត្រខ្មែរ

ក្នុងសម័យថ្មីនេះ ប្រសិនបើលើកយកចម្រៀងអ្នកស្រុកនិងរឿងព្រេង ដែលនិយាយមាត់ទន្ទេរនោះចេញ យើញថាអក្សរសាស្ត្របស់ស្រុក សម័យថ្មីនេះ មិនមានរសជាតិដើមនិងដំណែលថ្លៃថ្លាជាងដុំឡើយ ។

ចុះហេតុអ្វីបានជាអក្សរសាស្ត្រខ្មែរមិនបានចំរើនដោយនូវមានរស ជាតិដើម ដែលអាចនឹងធ្វើឲ្យយើញបានខ្លះ រស្មីរបស់ជនជាតិមួយដែល ភ្ជាប់មានថ្លៃដែនឹងគេ គ្រប់ជនជាតិសៀមដែលមានវឌ្ឍនធម៌សឹងដូចគ្នា នឹងជនជាតិជិតខាងនៅទិសខាងកើតនោះ ហើយបានធ្វើការកសាងអក្សរ-សាស្ត្រដូចគ្នានោះដែរ ម្តេចក៏គេបង្កបង្កើតបានក្បួនខ្នាតរឿងព័ន្ធខ្លះមាន ដំណែលដ៏ពិតៗនោះបាន ? ពិនិត្យរកហេតុផលនេះទៅ យើញថាប្រហែល ជាមកអំពីប្រទេសខ្មែរចេះតែមានគ្រោះថ្នាក់ឥតស្រាកស្រាន្តតាំងអំពី សតវត្សរ៍ទី ១៥ មក ។ ហើយគ្រាយដែលអង្គរអន្តរាយធ្លាក់ចុះទៅនោះ ពង្សាវតារបស់ប្រទេសខ្មែរសឹងមានតែការពាក់ព័ន្ធរឿយៗ រឿងចម្បាំងកំណ ដល់បាត់ជ័យនោះឯង ។ ព្រះពុទ្ធសាសនាមានការដែលត្រូវធ្វើ មិន អាចនឹងគិតគូរបណ្តុះបណ្តាលអក្សរសាស្ត្រនឹងរបស់ជាតិឲ្យចំរើនបាន ប្រជាកស្ត្រៃដែងមានសេចក្តីសប្បាយក្នុងការចិញ្ចឹមជីវិត ។ មួយវិញទៀត យើងត្រូវលើកយកហេតុដែលព្រះពុទ្ធសាសនាមកផ្សាយឥទ្ធិពលលើ អារ្យធម៌ជាន់ចាស់របស់ខ្មែរ ។ សង្ខេបអំពីការផ្សាយនឹងនាំអារ្យធម៌ចូល ទៅក្នុងប្រទេសថៃ គាលពីសតវត្សរ៍ទី ១៣-១៤ ដែលថៃមានវឌ្ឍនធម៌

នៅជារបៀបមនុស្សជាន់ដើមច្រើនជាងខ្មែរនៅឡើយ កិច្ចការទាំងនោះ ហើយដែលគួរនាំយកមកពោលជាហេតុដែលធ្វើឲ្យអក្សរសាស្ត្រខ្មែរមិនមានសេចក្តីចំរើនតាមកដល់សម័យក្រោយនេះ ក្នុងខណៈដែលជនជាតិសៀមបានបង្កើតជាវរត្ត ១ ជាដំបូង គឺសិលាចារឹកយ៉ាងល្អចំណាន ៖ បស់ព្រះបាទកមតំហែង ដែលជាសម្រែកសំដែងជ័យជំនះនឹងឫទ្ធានុភាពនាំឲ្យឃើញថា អាណាចក្រខ្មែរបុកណាចាប់ផ្តើមខ្ទុះគ្រាមចុះតាំងតែអំពីនោះមក (ចុងសតវត្សរ៍ទី ១៣) ។

មុននឹងពិនិត្យមើលប្រភេទអក្សរសាស្ត្រផ្សេងៗក្នុងចំណោមអក្សរសាស្ត្រខ្មែរទំនើបថ្មីនោះ យើងត្រូវតែបញ្ជាក់ជាមុនថា ក្បួនខ្នាតនឹងសាស្ត្រារឿងផ្សេងៗរបស់ខ្មែរ ច្រើនតែគ្មានឈ្មោះអ្នកតែងនឹងគ្មានថ្ងៃខែឆ្នាំជាប្រាកដ ។ តាលេពីសតវត្សរ៍ទី ១៨ គេបានដឹងថា អ្នកតែងរឿងអស់នោះគឺព្រះបាទព្រះអង្គដួង (ព. ស. ២៣៨៤-២៤០៦) ពួកចិន្តកវីខ្លះនៅក្នុងព្រះរាជសំណាក់ ពួកលោកសង្ឃខ្លះក្នុងចំណោមលោកសង្ឃនេះ មានសម្តេចព្រះមហាសង្ឃរាជដែលសុគតក្នុង ព. ស. ២៤៥៧ ។

ពាក្យកាព្យឃ្លោង – ភាសាដែលចិន្តកវីចង់ក្រងឡើងជាពាក្យកាព្យសឹងមានខំនងខុសគ្នាឆ្ងាយពីរបៀបនិយាយប្រៀបសរសេរធម្មតា ភាសា

ចំណុកវិនោះ សំដីដេរជាសដោយភាសាសំដីបុរាណនឹងពាក្យពេចន៍ដែលខ្ចីយកមកពីភាសាសំស្ក្រឹតនឹងភាសាបាឡី ។ ចំពោះពួកបណ្ឌិត គេទុកការចេះដឹង ការរុករកការរៀនសូត្រចេស់អ្នកតែងរឿង ជាការគាប់ប្រសើរនៃការតែងកាព្យឃ្លោង ច្រើនជាជាងការសម្រើបចិត្តប្លែកៗបាយនាំឲ្យសម្រើបចិត្ត ។ ដោយហេតុនោះហើយបានជាពួកកាព្យឃ្លោងដែលមានរបៀបបែបដែនជាក្បួនខ្នាតសម្រាប់ក្មេងរៀនមើលនៅតាមវត្តនោះ ក្មេងមើលជាច់អស់ ប៉ុន្តែមិនអាចយល់សេចក្តីថាដូចម្តេចឡើយ ហើយមនុស្សចាស់ក៏មិនងាយនឹងពន្យល់ឲ្យច្បាស់លាស់បានដែរ ។

ក៏រីតែងកាព្យឃ្លោងខ្មែរនេះ អាស្រ័យនៅលើចំនួនព្យាង្គនឹងសម្ផស្សឃ្លោង តែសម្ផស្សឃ្លោងមិនចេះតែចាប់ចុងបួននៅចុងឃ្លោងនិច្ចទេ គឺចុងឃ្លោអាចមានចុងបួននឹងព្យាង្គណាមួយនៅក្នុងឃ្លោពាក្យមួយដងខ្មែរក៏បានស្រេចតែចាប់សម្រាប់រំពឹងតែងកាព្យនីមួយៗ ។ ការប្រើព្យាង្គដដែលៗក៏ជាវិធីមួយក្នុងការតែងកាព្យឃ្លោងនោះដែរ កាលបើតែងជារឿងល្ងែនឃ្លោពាព្យនីមួយ ។ ច្រើនតែប្រកបដោយការតម្រង់ទៅខាងចិត្តគំនិតនឹងទៅតាមដំណើររឿង ។ ស្រៅអំពីឃ្លោល្បែងដែលគេធ្លាប់ប្រើជាធម្មតាដែលមានចំនួនប្រហែលជា ១៦ បែបនោះ នៅមានឃ្លោល្បែងបែបគេបង្កើតដោយខ្លួនឯង ដែលជាការសមហាត់ឃ្លោល្បែងលេងពិតៗ ឥតមានសំដែងឲ្យ

យើញគំនិតឬទំនៀមចិត្តរបស់អ្នកតែង នោះទេ ។ ពាក្យកាព្យដែលមានរបៀបយែបយែន ហើយគេចុកជាក្បួនខ្នាតដ៏ពិតប្រាកដនោះ សឹងសុទ្ធតែជាក្បួនរួមប្រមូលកាព្យឃ្លោងសំដែងអំពីឧភាគជម្ងឺខ្លាន ដែលច្រើនតែជារបស់បុរាណ ។ មានជាតិខ្មែរតិចទេ ដែលមិនចេះចាំមាត់ទូរច្បាប់ក្រមជាតម្រាស៊ីវិល ច្បាប់ប្រុសជាតម្រាសម្រាប់កូនប្រុស ច្បាប់ស្រីជាឧភាគដំបូន្មានសម្រាប់កូនស្រី (ដែលគេនិយមថាជាស្នាព្រះហស្តព្រះអង្គដួង) សាស្ត្រាគ្រេះកាល កូនចៅ នឹងពពួកច្បាប់សាស្ត្រាជាដៃ។ទៀត ដែលមានលក្ខណៈដូចគ្នានេះ ខ្មែរដែលធ្លាប់រៀនទន្ទេញចេះចាំច្បាប់ចាំងនោះ ដែលមានលាយឡំទូវព្រះពុទ្ធបញ្ញត្តិព្រមចាំងរបៀបទំនៀមទំលាប់របស់ខ្មែរក៏ចេះរើសយកច្បាប់ចាំងនោះមកប្រើជាច្បាប់សម្រាប់ខ្លួនតម្រូវតាមឧភាគផ្សេងៗ ក្នុងកិច្ចចិញ្ចឹមជីវិត ។

ពពួកអក្សរសាស្ត្រដែលជាពាក្យកាព្យ ច្រើនតែជាសាស្ត្រាល្បែងដែលដកស្រង់យកពីរឿងពាមក្រវ៉ាំ ឬរឿងកូនតម្លាបញ្ញាសជាគក ដែលតមកជាន់ក្រោយ លោកសង្ឃរាជបានបញ្ចូលរឿងព្រៃនផ្សេងៗរបស់ប្រទេសឥណ្ឌូស៊ីនទៅក្នុងនោះថែមទៀត ។ ក្នុងសាស្ត្រាល្បែងចាំងនោះអ្នកតែងតួនីមួយៗ សឹងនិយមធ្វើតាមដំណើររឿងឥណ្ឌៀ ដែលតែងជាកាព្យឃ្លោង ។

ចប្រាប់រឿងស្លាត

បទត្រែហ្មតឹត

១ ព្រះខាន់ហើយឥតស្រមោ នាផ្ទះក្រោមឥតមន្ត្រី ក្សត្រៃយ៍ពុំចេះគម្ពីរ ស្រីឥតគម្តែងក្រឡា ។ កើតមកជាបុត្រក្សត្រៃយ៍ ពុំប្រយ័ត្នរៀនសាស្ត្រា ពុំរៀនតិចារណា ពុំដឹងក្រឯទុក្ខកស្តួ ។ ពុំដំកើងពាក្យពិត បញ្ឆៃធ្វើសិលវិនាស យកតរលោយកប្បាស កុំយកមាសលាយនឹងប្រាក់ ។ ប្រើត្រាប់ឯត្រាជ្ជ កុំបង់ផ្លូវដោយតម្រាស់ កុំដឹងរវេះចាស់ ចាចសាចខ្ជាប់កំបុតគ្នង ។ ជាក្សត្រៃយ៍ពុំរៀនធម៌ ពុំដោះសាជម្ងឺខ្លួន ក្រស្តាសនឹងចំកោង អាក់ចិត្តខឹងសត្វចោមកោម ។ នឹងកើតក្តៅក្រហាយ ទុក្ខអន្តរាយកពីផ្ទះក្រោម ក្រស្តាផងនឹងខឹងចោមជ្រោមខ្ពាត់ខ្ពាយពីណា ។ រឹមត្រែសង្ឃរស្មេហ៍ កុំបីប្រែតែពាក្យថា ស្រឡាញ់ខ្លួនសត្វា កុំបីស្តប់ឱ្យសាមន្យ ។ អ្នកកាចសារពើក្តី សឹងអប្រិយវាសួលប្លាណ តើតទោសអាត្មាមាន គំនូរខុសជាអសារ ។ ទោះឆ្លងព្រះគង្គា សាត់អាត្មាកណ្តាលវាល ពាសឹកដេញប្រហារ រត់ចេញទៅប្រទេសខ្លា ។ ប្រទេសពាំងពាកឈើង សឹងជាប់ឡើងខាំអាត្មា ចំរូងច្រែងចង្វា ជាប់ដោយដើងជាន់ជិតដី ។ ខ្លោចក្សត្រីស្តាន តោសនឹងមានភ្លូមិលំនៅ បឹតខ្លែប្រែក្តាត់ក្តៅ សឹងហួនសៅធ្វើទោសណា ។ ពាំងនាយ

ពុំរក្សា ចៀនបំណាងពុំឲ្យថ្លើង អស់ញាតិពុំបន្ទើង សឹងវត់ចៀសចេញ
ទៅឆ្ងាយ ។ ពីងថ្នាលៗសោតថ្កាក់ ខ្លួកពំនាក់ក្លួកត្រាត់ត្រាយ ពីង
បុណ្យថ្កាបកំពាយ សាត់គយ្ហាយដោយខ្យល់នាំ ។ កុំឲ្យចង្វាចក សូវចុះ
ទឹកត្រតើទាំ អត័ព្វខៅសាំពាំ ជាទុក្ខសោកខៅស្ងួតស្ងក់ ។ ខ្លួវកើតឯ
ហោចហិន ត្រមោចក្បាលវិងអាក្រក់ អំពើដ៏លាមក ខ្លួវកើតខោស
ជាសាមាទ្យ ។ ដូចពាក្យនៃមនុស្សផង ស្រដីគ្គឆ៍ឥតប្រមាណ ពោល
ពាក្យពាវបំពាន ពុំរំពឹងឯក្រោយក្អែក ។ ពានពុំដែលស្ទ័គ្រ ស្រី
សាធស័ក្តិពុំដែលស្រែក រីឯមៀមនឹងក្អែក ពុំដែលរួមទ្រនំគ្នា ។ ខោះ
អ្នកជាតិព្រៃព្រឹទ្ធ ចាំរិះរិតបុពណា គួរចង់ចិត្តស្នេហា សារពើតិតកេរ្តិ
សព្វស្ថាន ។ យកខាលជង់សំណ ដោយចិត្តឆគិតឲ្យបាន រលាយឯខាល
ការណ សឹងពុំបានចង់ខាលសោត ។ ប្រទះបោះកាំបិត ចង់សុចរិតនៃ
អ្នកឆោត ចង់ពីរប្រការសោត ត្រូវដំខៀលលោតនិន្ទា ។ កុំកាន់ពាក្យ
អស័ត្យ ប្រុងប្រយ័ត្នអង្គអាត្ម ដ៏លោកបរលោកា បរិបូណ៌បានសុខ
សួស្តី ។ កុំពោលពាក្យមុសា ភាវភាចាឲ្យមានហ្មង ចំពួកសត្រូវផង
តែងយកខោសនៃអាត្ម ។ កុំពោលពាក្យចំពាន តែងនឹងមានដំខៀលថា
ខុយ័សពិតពុំជា ខ្លួវខ្ចាសមុខឯងសព្វថ្ងៃ ។ យកខ្លោចគេមកយំ មើល
ផ្សុំថ្នាំពាធ៌ហិនវិហ ពុំនឹរពុំប្រពៃ ពុំបានជាប្រយោជន៍អង្គ ។ ធ្វើគុណ

តើតជាគោស យកឈ្មីន៍ច្រាសក្នងអន្ទង់ យកប៉ុយទៅគ្រប់ក្តើង គុណ
ប្រទ្បង់អម្បោះផ្កាយ ។ អណ្តើកអម្ចាស់មាន ហ៊ានលក្ខនពានយកស្មោរ
ជាយ ក្រួចដូរពុំដូរក្លាយ ពុំប្រយ័ត្នគេយកបាន ។ ហេតុចិត្តពុំតិតធ្វែ
អំពីកែពន់ក្រមាណ អ្នកថ្លស់យសពីច្រណ ចិត្តពុំក្សន្តពុំសោយ ។
អ្នកខ្ជិលចង់តែស៊ី អ្នកអប្រិយមើលងាយគេ រក្សាច្រែនដាផាយ ទ្រព្យ
ភ្ជាត់ភ្ជាយរង្គ្គានឡើង ។ ជំរីសារចូលទៅ កន្ងអំពៅនោះលើង ពាំង
គុម្ពល្អិតដោយដើង នៃជំរីសារចូលហោង ។ អំពៅអំពល់អស់ រលើង
ប្លុសពាំងគុម្ពផង ពាំងស្រែចំការគ្រង ហានលំនៅឥតអាស្រ័យ ។ អ្នក
ខ្លាចអ្នកអាងហ៊ាន ស្រដ៏កនក្លួតដើងដៃ កំឡាំងមានស្មើថែ ទើងបើអ្នក
អាងសាធារណ៍ ។ អែ្នកជាតាហាន ស្ងៀមនៅហានពុំចរចា សន្សឹម
កេស៊ីស្ងា លុះសឹកដល់បន្ទឹមាត់ ។ ដូចស្បែកភ្លុកខ្លួ សឹងសាយគួរគង់
ពុំបាត់ កាលស្លាប់គេលះលាត់ លាយយល់ស្លាត់ដូចដែលហោង ។
ដូចតុតតាលពុំជា កុំផ្តន្ទាទោសទណ្ឌផង ថងតប់ជាល់ក់យចង ពុំបេះ
ចាលពុតបាត់បង់ ។

(នៅមានត)

ជាសាវកសាវិការបស់ព្រះពុទ្ធជាម្ចាស់

២— សុទត្ត-គហបតី- នេះជាឈ្មោះដើមរបស់អនាថបិណ្ឌិកសេដ្ឋី ខ្ញុំឯង លោកជាបុត្រៃរបស់សុមនសេដ្ឋីកងនគរសាវត្ថី កាលចំរើនវ័យធំឡើងហើយ ក៏បានគ្រប់គ្រងផ្ទះសំបែងតាមឃុកឋសវ័យ ជាអ្នកមានចិត្តជាកុសល តែងចំនុកបំរុងសមណព្រាហ្មណ៍រហូតដល់មនុស្សអនាថា ទើបមាននាមប្បញ្ញត្តិឡើងថ្មីថា អនាថបិណ្ឌិកៈ ប្រែថាអ្នកមានដុំបាយសម្រាប់ចំនុកបំរុងមនុស្សអនាថា ។ មានសេចក្តីដំណាលថា សម័យមួយលោកបានផ្គុំរបស់ដោយរាះចំនួន ៥០០ ទៅកាន់ផ្ទះរបស់សំឡាញ់កងក្រុងរាជគ្រឹះ ហើយលោកបានស្គាល់ព្រះបរមសាស្តានៅទីនោះ បានស្តាប់ព្រះធម្មទេសនា បានសម្រេចសោតាបត្តិផល ។ ក្នុងថ្ងៃជាគំរប់ពីរ លោកអនាថបិណ្ឌិកសេដ្ឋីបានថ្វាយមហាទាន ហើយក្រាបទូលទៅមន្តសម្តេចព្រះបរមសាស្តាឲ្យស្តេចទៅកាន់ក្រុងសាវត្ថីផង ទើបលោកកសាងព្រះជេតវនមហាវិហារថ្វាយ ដោយការបរិច្ចាគទ្រព្យ ៥៤ កោដិកហាបណៈ ហើយបានថ្វាយកត្តិផ្សែងៗជានិច្ច ជាមហាឧបាសកដែលមានសទ្ធាជ្រះថ្លាយ៉ាងក្រៃលែងក្នុងព្រះពុទ្ធសាសនា ដោយអាស្រ័យហេតុនេះ ទើបព្រះបរមសាស្តាទ្រង់តាំងលោកក្នុងដំណែងដែលប្រសើរលើសលែងជាងឧបាសកទាំងឡាយរួមកថ្វាយទាន ។

លោកអនាថបិណ្ឌិកសេដ្ឋីនេះ ល្បីថាជាអ្នកបរិច្ចាគទានក្នុងព្រះពុទ្ធសាសនា ដរាបដល់អស់ទ្រព្យសម្បត្តិរលីងតែតមកគ្រាយទៀតបានតែ

កុនមានទ្រព្យសម្បត្តិស្តុកស្តម្ភឡើងវិញ ។ លោកមានកូនប្រុស ១ ឈ្មោះ
ខេមក: ជាន់ដំបូងជាមនុស្សស្រែវាងនឹងរូបសម្បត្តិ ដល់ទៅបិតាគោងជួល
ឲ្យទៅស្តាប់ធម៌ទេសនាទើបត្រមទៅតាម ក៏ត្រឡប់ជាអ្នកប្រពឹត្តល្អ ។
ឯកូនស្រីលោកមាន ៣ នាក់ ទី ១ ឈ្មោះមហាសុកដ្ឋ ទី ២ ឈ្មោះ
បុល្លសុកដ្ឋ ទី ៣ ឈ្មោះសុមនា ។ សេដ្ឋីជាបិតាជាអ្នកមានសទ្ធាជ្រះថ្លា
ខ្ជាប់ខ្ជួនក្នុងព្រះពុទ្ធសាសនា តែងថ្វាយទានទៅកាន់ផ្ទះរបស់ខ្លួនជានិច្ច តែខ្លួន
លោកជាទានបតី អ្នកស្រុកពាប់អានថាជាមង្គល បើអ្នកណាទំនងធ្វើបុណ្យ
ទានអ្វី ច្រើនតែអញ្ជើញលោកមិនសូវដែលខាន ទើបមិនមានឧកាសចាត់
ការអង្គាសព្រះភិក្ខុសង្ឃដោយខ្លួនលោកទៅផ្ទះរបស់ខ្លួន ទើបសេដ្ឋីតាំង
នាងមហាសុកដ្ឋឲ្យជាអ្នកចាត់ចែងធ្វើទានជំនួសខ្លួន ។ លុះនាងបាន
សម្រេចសោតា ទៅកាន់ត្រកូលស្វាមីហើយ ទើបតាំងនាងបុល្លសុកដ្ឋធ្វើ
ការនោះជំនួស លុះនាងបានសម្រេចសោតាវិញទៅកាន់ត្រកូលស្វាមីហើយ
ទើបសេដ្ឋីតាំងនាងសុមនាជាប្អូនទៅជំនួស តមកនាងបានសម្រេចអនា
គាមិផល តែជាស្ត្រីមានភេគច្រើន ទើបអនិច្ចកម្មទៅតាំងពីនៅក្មេង ធ្វើឲ្យ
សេដ្ឋីបិតាសៅសោកជាខ្លាំង ទើបទៅក្រាបទូលអំពីបុត្តវិយោគដល់ព្រះ
សាស្តា ។ ទ្រង់សំដែងធម៌ទ្រាប់សេចក្តីសៅសោកបាន ។ ឯខ្លួនលោកកាល
មានអាយុសង្ខារសេមគួរនឹងកាលវេលាហើយ ក៏អនិច្ចកម្មទៅ ។

ចប់ប្រវត្តិសង្ខេប របស់អនាថបិណ្ឌិកសេដ្ឋីតែប៉ុណ្ណោះ ។

(តមក)

កាលបើបានចាត់របៀបអនុញ្ញាតឲ្យប្រជាជនធ្វើពាហានបានហើយ ពាជការពាហានក៏ចាត់ជាកិច្ចមួយ ដែលពាជការត្រូវចាត់របៀបឲ្យមានឡើង ។ សការសេណាត៍ជាអ្នកកំណត់ថាត្រូវចាត់ឲ្យមានពាហានប៉ុន្មានក្រុម កុងស៊ុលជាអ្នកកំណត់ថ្លៃហៅប្រដុំពួកដំណាងក្រុង ។ រីឯរ៉ែសមនុស្សមកធ្វើពាហានប្រើវិធីចាប់ឆ្នោតជាមុន រួចទើបគេជ្រើសរូបនីមួយៗជាក្រោយ ក្រុងណាដែលមិនបានមកចូលប្រដុំត្រូវធ្វើពេលជាទម្ងន់ដូចជាលក់តិន័យ, ពយ, ជាក់គុកឬចាប់ខ្លួនធ្វើជាខ្ញុំក៏មាន កាលបើរ៉ែសបានគ្រប់ចំនួនតាមសេចក្តីត្រូវការហើយ ទើបឈប់ហៅ ។

ពាហានភេមជាចំនួនច្រើន សុទ្ធតែជាស្បែស្រឡាយជាតិឡាតាំង តាមធម្មតាជាអ្នកមានរូបកាយមិនធំស្រោងទេ ច្រើនតែមានកាយជាត់ធំវែងរ៉ែង ឆ្ងាប់ធ្វើការងារនៅទីលស្រែមកជាច្រើន ទើបមានអំណាត់អត់ធ្មត់មិនសូវខ្សឹយហត់ងាយ ។ ឯសេចក្តីអត់ធន់នេះ ជាគុណសម្បត្តិដ៏សំខាន់មួយដែលពាហានភេម៉ាំងបានទទួលសេចក្តីសរសើរមកច្រើនបំផុត ដូចជាពាហានថ្មើរជើង អាចចេញដើរតែមួយដើងកងចម្ងាយផ្លូវតាំងអំពី ២៨ ដល់ ៣២ គីឡូម៉ែត្រ ព្រមទាំងរបស់យកទៅផង មានទម្ងន់ ២០ គីឡូក្រាម ព្រោះស្បែរ៉ែងស្បែរ៉ែងនឹងស្បែរ៉ែងអាវុធក្នុងរូបខ្លួនមនុស្ស

ម្នាក់ៗ នៅត្រូវមានពូថៅនឹងបបរបែល សម្រាប់ប្រើធ្វើនាទីជាពាហនជាដើម ហើយគាងផ្តុតត្រឿងអាហារគោជនសម្រាប់បរិភោគឲ្យល្មមគ្រប់គ្រាន់ក្នុងរវាង ១៥ ថ្ងៃជាដើម ។ កាលបើដល់ដំណាក់ផ្លូវនីមួយៗ ក៏ត្រូវតែកសាងបន្ទាយគ្រប់អន្លើ ដោយហេតុនេះពាហនពេម៉ាំងគ្រប់គ្នាទើបត្រូវតែមានលក្ខណៈ៣ ប្រការ គឺជាអ្នកដើរមិនសូវនឿយហត់ ជាអ្នកឆ្បាំងដ៏ក្លាហានហើយជាជាងដែលមានថ្វីដៃពូកែជាដើម ។

ចំណែកខាងចិត្តថ្មើម ពួកពេម៉ាំងជាជាតិដែលស្តាប់នាយពៅហ្វុយជាទីបំផុត ។នេះហើយជាមូលហេតុដ៏សំខាន់ ដែលធ្វើឲ្យជាតិពេម៉ាំងជាម្ចាស់លោក ។ ជនជាតិពេម៉ាំងជាប្រជាជនដែលមានសេចក្តីព្យាយាមនឹងស៊ូគ្រប់គ្រងលះបង់អ្វីៗដើម្បីប្រទេសជាតិរបស់ខ្លួន មិនបេះធុញថប់អស់សេចក្តីមានៈ កាលបើពៅឆ្បាំងចាញ់គេឬធ្វើការមិនសម្រេច ។ ។នេះពុកជាពួកសត្រូវពេម៉ាំងក៏មានសេចក្តីសរសើរ ក្រៅពីនេះ ក្រុមពាហនពេម៉ាំងគោរ.ធ្វើពិធីស្បថ ដែលមានសេចក្តីសំខាន់ គឺការត្រូវដឹស្តាប់ពាក្យបង្គាប់របស់មេទ័ព ហើយត្រូវពៅតាមមេទ័ពរបស់ខ្លួនគ្រប់គ្រងអន្លើ ស្រែចតែមេទ័ពនាំពៅ ហើយត្រូវពៅក្រោមម្លប់ទង់ជ័យរបស់ពាហន ទម្រាំតែដល់ផុតកំណត់ពាក្យសំបថនោះ ។ វិធីធ្វើពាក្យសត្យសំបថនេះ ពួកមេពាហនគោរ.ផ្តើមធ្វើជាមុន រួចយកពាក្យសំបថនោះពៅមើលកងកងពាហន កាលបើមើលចប់ហើយ យកបញ្ជីឈ្មោះ

ភាហានមកហៅឈ្មោះគ្រប់ៗគ្នា អ្នកដែលត្រូវហៅឈ្មោះខ្លួនតោងឆ្លើយថា "ខ្ញុំបាទ" ផង ។

ពួកភាហានកេមុាំងតោងកាន់ច្បាប់វិន័យភាហានយ៉ាងម៉ឺងម៉ាត់បំផុត ពួកមេព័ទបង្គាប់ឲ្យកូនភាហានដើរផ្លូវត្រួយៗធ្វើការយ៉ាងធ្ងន់ ទំងន់ធ្ងៃទោសជាទម្ងន់ ។ ការទំងន់រំងូសមិនស្តាប់បង្គាប់មេព័ទ មិនថាកងកិច្ចការណាមួយទេ តោងតែត្រូវទោសដល់ប្រហារជីវិត មុនទំងន់ប្រហារជីវិតត្រូវចាប់វាយគ្រាតែទ្រមគ្រាំគ្រា ហើយការធ្ងៃទោសបែបនេះ មិនកំណត់ថាជាមនុស្សប៉ាន់ណាទេ តោងត្រូវទោសដូចគ្នាទាំងអស់ ។ កូនប្រុសម្ចាក់របស់ ម៉ុនលីយុស ធ្លើជាកុងស៊ុលក៏នៅតែត្រូវទោសដល់ប្រហារជីវិតមិនមែនដោយហេតុថៅធ្លើខុសច្បាប់ឬមិនធ្លើតាមបង្គាប់មេព័ទទេ គឺដោយហេតុខ្លួនច្បាំងចាញ់ភាហានគោល្លកងការតទល់គ្នាតែម្ចាក់ទំងន់ម្ចាក់ដូរតាមគំនិតពួកកេមុាំងក្នុងសម័យនោះ ប្រកាន់ថាជាការគាំរះមុះណាស់គួរតែសិក្សាប់ថៅវិញប្រសើរជាង ។

បើបែរជាកំហុសរបស់ភាហានចាំងក្រុមឬចាំងកង ច្រើនតែធ្លើទោសដោយវិធីចាប់ស្លាក គឺចាប់យកម្ចាក់ក្នុងចំនួន ១០ នាក់ឬ ២០ នាក់ហើយយកពួថៅកាប់កាត់កចោល ។ តាមធម្មតា ពួកភាហានកេមុាំងដែលធ្លាយឲ្យពួកសត្រូវចាប់ខ្លួនធ្លើជាឈ្លើយនោះ មានសង្ឃឹមតិចណាស់ក្នុងការដែលឲ្យរដ្ឋបាលខ្លួនជួយដោះខ្លួនឲ្យបានត្រឡប់មកស្រុកទេសវិញ ។ ឆ្លាប់

មានចម្បាំងមួយ ក្នុងកងក្រុងកេមទីដ៏ការជាស័ ពួកឥស្លាមប្រហែល ៨០០០ នាក់ ត្រូវពួកឥស្លាមការជាស័ចាប់យកទៅធ្វើជាឈ្លើយ ។ រឿងនេះ តាមធម្មតា រដ្ឋបាលគោរសុំទិញដោះខ្លួនឥស្លាមមកស្រុកវិញ តែក្នុងសម័យនោះ សភាសេណាត់មិនត្រូវទិញ ទើបពួកឥស្លាមកេម៉ាំងចាំង ៨០០០ នាក់ ត្រូវចាប់ខ្លួនលក់ជាខ្ញុំអស់ទៅ ដែលជាការធ្វើទោសយ៉ាងធ្ងន់មួយយ៉ាង ។

ឯបំណាច់ផ្ទាន់ដែលត្រូវចែកដល់ពួកឥស្លាម ដែលមានជ័យជំនះវិញក៏សំបើមណាស់ដែរ មានការឲ្យដួងត្រាឲ្យមកពុជ ហើយមានដួងការឲ្យប្រាក់ជាច្រើនផង ។ មេទ័ពណាដែលទៅច្បាំងឈ្នះ ដល់ត្រឡប់មកវិញមានការទទួលយ៉ាប់ជាពិធីដ៏ធំវិត្រលែង ខ្លួនមេទ័ពនេះចូលកាន់ក្រុងកេមដោយរថទឹមសេះ ៤ នៅខាងមុខរថមេទ័ពនេះ មានពួកឈ្លើយទឹងទ្រព្យសម្បត្តិដែលប្លន់យកបកបាន ឬដែលរឹបជាន់មកពីពួកសឹកសត្រូវ ។ បើមានចម្បាំងធំទឹងមានជ័យជំនះយ៉ាងធំហើយ ការធ្វើពិធីទទួលមេទ័ពដែលមានជ័យ ដើរចូលកាន់ក្រុងកេមនេះជាទម្លាប់តមហាមា ដូចជាកាលត្រាច្បាំងឈ្នះពួកម៉ាសេដូន នោះគោរធ្វើពិធីដើរទ័ពចូលកាន់ក្រុងកេមជាវេលា ៣ ថ្ងៃទើបផុតក្បួនដើរទ័ព ។ មេទ័ពដែលមានជ័យជំនះ ក៏ចោមរោមទៅដោយពួកឥស្លាមដែលកាន់ផ្ទួងផ្ការីងរីស្រែកច្រៀងក្រៀងជ័យ ។ កាលចូលដល់ក្រុងហើយ ក៏ចាប់យកពួកមេទ័ពមេកងខាងសត្រូវដែលចាប់ឃុំខ្លួនបានមកនោះ ទៅជាក់គុកហើយច្រចាច់តសម្លាប់ ។

(នៅមានត)

រឿងជីងសងជីង-អ៊ំបែងសងអ៊ំបែង

មាននិទានមួយដំណាលថា មានបុរសប្តីប្រពន្ធមានកូនប្រុសម្នាក់ ។ បុរសជាប្តីនោះទៅខ្ចីដីងអំពីសេដ្ឋីម្នាក់យកទៅកាប់ទុស លុះលើកឡើងទីងសំពង់កាប់ ស្រាប់តែដីងនោះរង្គោះផ្ទៃខ្លួនទៅត្រូវប្រឹសមួយកប់ជាប់កងខ្នងប្រឹសនោះ ។ក៏ចោលចូលព្រៃតាមរកពុំឃើញឡើយ បុរសនោះក៏វិលមកផ្ទះអាត្មា ប្រាប់ប្រពន្ធកូនរួចហើយទើបទៅប្រាប់សេដ្ឋីដោយខ្លួវដំណើរដីងជាត់នោះ ។ សេដ្ឋីថា ដីងនោះជារបស់តំណត់កម្រពីមុនអញ បើឥតអំពីដីងនេះហើយ អញគ្មានអ្វីប្រើការឡើយ ។ បុរសនោះអង្វរសុំសងជាដីងមួយថ្មីវិញ សេដ្ឋីពុំព្រមនិយាយថាឲ្យបានដីងដើមទើបយក ទុកជាបុរសនោះអង្វរសុំសងមួយជាពីរក៏សេដ្ឋីពុំព្រមយកឡើយ ។ បុរសនោះក៏វិលទៅគិតនឹងប្រពន្ធរួចត្រឡប់ទៅរកសេដ្ឋីទៀត អង្វរសុំសងមួយជាបួន សេដ្ឋីនៅតែពុំព្រមយក សងមួយជាដប់សេដ្ឋីក៏ពុំយកទៀត នៅតែនិយាយទទូចថាឲ្យបានដីងដើមនោះទើបយក ។ បុរសនោះលាសេដ្ឋីវិលទៅគិតនឹងប្រពន្ធត្រមត្រៀនគ្នាថា ត្រូវយកកូនកំឡោះធ្វើជាសំណាងវិញ ។

លុះគិតដូច្នោះហើយ បុរសនោះក៏នាំកូនកំឡោះទៅប្រគល់សេដ្ឋីជាសំណាងដីងនោះ សេដ្ឋីក៏ព្រមទទួលយក ។ ឯបុរសនោះក៏វិលទៅ

ផ្ទះអាត្មាវិញហើយទៅកុំសក្តងវៃព្រៃទៀតស្រាប់តែឃើញប្រើសនោះដឹកលុយទៅហើយៗឃើញគាំងដឹងនោះផង មានសេចក្តីត្រេកអរឥតឧបមានាំយកមកផ្ទះ ស្គាល់ជាក់ជាដឹងរបស់មហាសេដ្ឋី ជូសលាងស្អាតហើយយកទៅជូនសេដ្ឋី ប្រាប់ដោយដំណើរនោះសព្វគ្រប់ហើយសុំយកកូនមកវិញ ។ ឯសេដ្ឋីស្គាល់ដឹងនោះជាក់ក៏ទទួលយកហើយឲ្យកូនតំឡោះទៅបុរសនោះៗនាំកូនទៅគាន់លំនៅរបស់ខ្លួន ។ ចំណេរកាលតមកជល់ដូវស្រែទុំ បុរសប្តីប្រពន្ធដាល់អំបុកស៊ី ។ កូនស្រីសេដ្ឋីនោះធុំក្លិនអំបុកក៏នឹកចង់ស៊ីហើយអង្វរម្តាយអាពុកឲ្យរកអម្បែងឲ្យ សេដ្ឋីរកខ្លីអម្បែងគេពុំបាន សោះ ក៏ចូលទៅខ្លីអម្បែងបុរសនោះ លុះដាល់អំបុកឆ្អែហើយ ចួនជាមានឆ្កែមកប្រទាំគ្នាពារលើអម្បែងនោះបែកក្អិតអស់ ។ សេដ្ឋីឲ្យទៅប្រាប់បុរសនោះៗយំគក់ទ្រូងថា អម្បែងនេះជារបស់កំសត់កម្រមែមាមក ត្រូវតែរកអម្បែងដើមមកសងវិញ ទុកជាសេដ្ឋីស្រដីថាទឹងសងមួយជាមួយក្តីជាពីរក្តី បុរសនោះពុំព្រមយកឡើយ គឺទទួចយកឲ្យបានតែអម្បែងដើមនោះឯង បើមិនបានអម្បែងនោះមិនព្រមទេ ។ ទើបសេដ្ឋីឲ្យទៅស្រដីថាទឹងសងមួយជាបួនក្តី មួយជាដប់វិញក្តី បុរសនោះក៏នៅតែពុំព្រមយកឡើយ ។ សេដ្ឋីខឹងក៏ទៅប្តឹងដល់ចៅក្រមៗឲ្យហៅបុរសនោះមកជណ្តឹងសួរដោយដំណើរហើយ ទើបចៅក្រមបង្គាប់ឲ្យសេដ្ឋី

នោះសង្ឃអម្បែងតែមួយ បុរសនោះពុំត្រមយកឡើយ ទៅត្រមក៏និយាយ
ថា ទៅបុរសនេះល្មើសនឹងបង្គាប់អញ ។ ឯសេដ្ឋីយល់បុរសនោះពុំសុខចិត្ត
ក៏នាំសេចក្តីឡើងទៅក្រាបបង្គំទូលសម្តេចព្រះមហាក្សត្រាធិរាជដោយដំ-
ណើរនោះ ទើបព្រះអង្គឲ្យហៅបុរសនោះមកហើយមានព្រះបន្ទូលជណ្តឹង
សួរថា ដំណើរនុ៎ះទៅត្រមបង្គាប់ក្តីហើយម៉េចក៏ព្រះស្តេងពុំសុខចិត្ត ។
បុរសនោះក្រាបទូលថា ដ្បិតសេដ្ឋីខ្ញុំអម្បែងខ្ញុំព្រះអង្គទៅជាលំអុបុក ពុក
ឲ្យផ្តែបែរាំគ្នាពារលើបែករបស់ខ្ញុំព្រះអង្គ ឯអម្បែងនោះជាកេរ្តិ៍ពីមេពីឪ
មក តែងនឹងចិញ្ចឹមជីវិតដោយសារអម្បែងនោះ ដូច្នេះលុះតែបានអម្បែង
ដើមទើបខ្ញុំព្រះអង្គយក បើកេពុំបានទេខ្ញុំព្រះអង្គពុំយកឡើយ ។ ទើបព្រះ
មហាក្សត្រទ្រង់ព្រះចិន្តាពិចារណាថា ការអស់នេះសមមានហេតុនឹងគ្នា
អំពីមុនបានជាកូចគាន់ខ្លាំងណាស់ ទើបត្រាស់ជណ្តឹងសួរថា ព្រះស្តេង
មានដំណើរហេតុដូចម្តេចអំពីដើមបានជាកូចគាន់គ្នាខ្លាំងម្ល៉េះ ។ បុរសនោះ
ក្រាបទូលថា ដំណើរដើមនោះគឺខ្ញុំព្រះអង្គខ្ចីដីងសេដ្ឋីទៅកាប់ឧសហើយ
រន្លោះផ្លែខ្លួតទៅត្រូវប្រើសមុតជាប់ទឹងខ្លួនវាឲ្យបាត់ទៅ ខ្ញុំព្រះអង្គរក
ពុំឃើញ បានទៅជ្រាប់សេដ្ឋីឲ្យដឹងនេះជាដឹងកំសត់កម្រពីមេពីឪ ខ្ញុំព្រះ
អង្គសុខចិត្តសងមួយជាពីរមួយជា ១០ ក្តី សេដ្ឋីក៏ពុំយកឡើយ ឲ្យបានតែ
ដឹងដើមទើបយក បើពុំបានដឹងដើមពុំយកឡើយ ។ សេដ្ឋីកូចគាន់ដូច្នេះ

ទើបខ្ញុំព្រះអង្គយកកូនឲ្យទៅនៅបំរើជាដំណួស ។ សេដ្ឋីក៏ទទួលយក លុះខ្ញុំព្រះអង្គទៅកន្លងបានពីរបីថ្ងៃក្រោយ ស្រាប់តែឃើញប្រើសនោះវិលត្រឡប់មកវិញ ហើយៗឃើញដីនៅកន្លែងនោះផង ខ្ញុំព្រះអង្គស្គាល់ជាកំជាដីនៃសេដ្ឋីហើយ មានចិត្តត្រេកអរណាស់ យកទៅឲ្យសេដ្ឋីៗស្គាល់ជាកំជារបស់ខ្លួនហើយ ក៏ទទួលយកហើយឲ្យកូនមកខ្ញុំព្រះអង្គវិញ ។ ព្រះមហាក្សត្រាធិរាជទ្រង់ព្រះសណ្តាប់ហើយ ទើបដណ្តឹងសួរសេដ្ឋីថា ដំណើរនុ៎ះដូច្នេះមែនឬទេ ? សេដ្ឋីក្រាបទូលថា ដូច្នេះមែន ។ ទើបព្រះអង្គមានព្រះបន្ទូលថា បើដូច្នោះសេដ្ឋីត្រូវឲ្យកូនខ្លួនទៅនៅបំរើគេវិញ ទើបគាប់ដោយគន្លងធម៌ ។ សេដ្ឋីនិងបុរសនោះក៏ក្រាបថ្វាយបង្គំទទួលព្រះបន្ទូលពីរសព្តាំងអស់គ្នា ។ សេចក្តីដែលសម្តែចព្រះមហាក្សត្រាធិរាជទ្រង់បង្គាប់ដូច្នេះ សេដ្ឋីនិងបុរសនោះបានចូលចិត្តស្តាប់ហើយ ក្រាបលាទៅកាន់លំនៅទីរៀងៗខ្លួន ។